# បទបញ្ញត្តិ ជាបទដ្ឋានអប្បបរមាសំរាប់ គ្រប់គ្រងអ្នកទោស

## មាតិការរឿង



| ល.រ | | ទំព័រ |
|---|---|---|
| ១ | **បទវិន័យនិងបទបញ្ហាចាំបាច់សំរាប់គ្រប់គ្រង អ្នកទោស ,កថាដើម** | ០៣-០៥ |
| ២ | **ជំពូក ១ ច្បាប់វិន័យសំរាប់ការអនុវត្តជាទូទៅ, គោលការណ៍ជាមូលដ្ឋាន** | ០៥ |
| | ការបែងចែកអ្នកទោសតាមជំពូក | ០៦ |
| | ទីកន្លែងសំរាប់អ្នកទោសស្នាក់នៅ | ០៦-០៧ |
| | អនាម័យប្រចាំកាយ | ០៨ |
| | ការស្លៀកពាក់និងការដេក | ០៨-០៩ |
| | ម្ហូបអាហារ | ០៩ |
| | ការហាត់ប្រាណនិងលេងកីឡា | ០៩ |
| | ការព្យាបាលជម្ងឺ | ១០-១២ |
| | វិន័យនិងទណ្ឌកម្ម | ១២-១៣ |
| | គ្រឿងប្រដាប់សំរាប់ឃុំខ្លួនអ្នកទោស | ១៤ |
| | មានសំរាប់អ្នកទោសនិងការតវ៉ាពីសំណាក់អ្នកទោស | ១៤-១៥ |
| | ការទាក់ទងអ្នកក្រៅ | ១៦ |
| | សៀវភៅអាន | ១៦ |
| | សាសនា | ១៧ |
| | ការដកហូតទ្រព្យសម្បត្តិប្រចាំកាយរបស់អ្នកទោស | ១៧ |
| | ការជូនពតិមានអំពីសេចក្តីស្លាប់, ជម្ងឺជំកាត់ឬការផ្លាស់ប្តូរទីកន្លែង | ១៨- ១៩ |
| | ការដឹកនាំអ្នុកទោស | ១៩ |
| | ភ្នាក់ងារប្រចាំមន្ទីរឃុំឃាំង | ១៩-២២ |
| | ការត្រួតពិនិត្យ | ២៣ |
| ៣ | **ជំពូក ២ បទវិន័យសំរាប់ប្រើប្រាស់តាមប្រភេទអ្នកទោស** | |
| | ក, អ្នកទោសដែលតុលាការវិនិច័យទោស (គោលការណ៍ណែនាំ) | ២៣-២៦ |




រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

| | | |
|---|---|---|
| | ការគ្រប់គ្រង | ២៧ |
| | ការចែកអ្នកទោសតាមប្រភេទលក្ខណៈនិងការគ្រប់គ្រងអ្នកទោសតាម វិធីម្នាក់ម្តង | ២៨ |
| | សិទ្ធិពិសេសតាមលក្ខណៈសម្បត្តិ | ២៩ |
| | ការងារ | ២៩-៣១ |
| | ការអប់រំនិងការកំសាន្ត | ៣១ |
| | ការទាក់ទងក្នុងសង្គមនិងការថែរក្សាក្រោយពីចេញពីមន្ទីរឃុំឃាំង | ៣២ |
| | ខ, អំពីអ្នកទោសឆ្កួតនិងអ្នកទោសដែលខូចខួរក្បាល | ៣៣ |
| | គ, ជនដែលត្រូវគេចាប់ខ្លួនឬរង់ចាំថ្ងៃ កាត់ទោស | ៣៣-៣៥ |
| | ឃ, អ្នកទោសបទរដ្ឋប្បវេណី (បទស៊ីវិល) | ៣៦ |
| | ង, មនុស្សដែលគេចាប់ឃុំឃាំងដោយគ្មានកំហុស | ៣៦ |



រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

# បទបញ្ញត្តិ ជាបទដ្ឋានអប្បបរមា

## សំរាប់គ្រប់គ្រងអ្នកទោស

Standard Minimum Rules for the Treatment of Prisoners

បានអនុម័តដោយសនិបាត របស់អង្គការសហប្រជាជាតិ លើកទីមួយស្តីពីការបង្ការបទឧក្រិដ្ឋនិងការប្រព្រឹត្តិលើអ្នកទោស ដែលបានប្រារព្ធនៅទីក្រុងហ្សឺណែវក្នុងឆ្នាំ ១៩៥៥ ហើយនឹងបានយល់ព្រមដោយក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម តាមសេចក្តីសំរេចលេខ ៦៦៣ ជ (XXIV) ចុះថ្ងៃ ទី ៣១ ខែ កក្កដា ១៩៥៧ និងសេចក្តីសម្រេចលេខ ២០៧៦ (LXII) ចុះថ្ងៃ ទី ១៣ ខែ ឧសភា ១៩៧៧ ។

Adopted by the First United Nations Congress on the Prevention of Crime and the Treatment of Offenders, held at Geneva in 1955, and approved by the Economic and Social Council by its resolutions 663 C (XXIV) of 31 July 1957 and 2076 (LXII) of 13 May 1977.

## បទវិន័យនិងបទបញ្ជាចាំបាច់

## សំរាប់គ្រប់គ្រងអ្នកទោស

### កថាដើម

១. បទបញ្ជាខាងក្រោមនេះ ពុំមែនជាការរៀបរាប់ពិស្តា (យ៉ាងសព្វគ្រប់) អំពីគំរូនៃរបៀបគ្រប់គ្រងនៅក្នុងមន្ទីរឃុំឃាំងទេ។ ដោយយោងទៅលើការស្របគំនិតគ្នាជាទូទៅ និងដោយយកគំនិតសំខាន់ៗនៃរបៀប (ប្រព័ន្ធ) គ្រប់គ្រងទូលំទូលាយ ដែលគេប្រើសព្វថ្ងៃនេះមកធ្វើជាមូលដ្ឋាន បទបញ្ជាខាងក្រោមនេះ គ្រាន់តែជាការរៀបរាប់ត្រួសៗអំពីរបៀបគ្រប់គ្រងជាទូទៅ មួយដែលគេចាត់ទុកថាល្អគ្រប់គ្រាន់ទាំងគោលការណ៍ ទាំងការអនុវត្តក្នុងវិស័យថែទាំអ្នកទោសនិងក្នុងវិស័យគ្រប់មន្ទីរឃុំឃាំង។

២. ក្នុងពិភពលោកទាំងមូលនេះដោយសារមានលក្ខណៈខុសប្លែកពីគ្នាច្រើនលើសលប់ពេកទាំងក្នុងវិស័យច្បាប់វិន័យ, វិស័យសេដ្ឋកិច្ច, វិស័យសង្គមកិច្ច និងវិស័យភូមិសាស្ត្រផងនោះ គេជឿជាក់ថា គេមិនអាចយកបទបញ្ជាទាំងអស់នេះទៅប្រើនៅ គ្រប់ទីកន្លែងបានគ្រប់ពេលវេលាទេ។ បទបញ្ជាទាំងនេះ គ្រាន់តែជាឧបករណ៍សំរាប់ជំរុញឲ្យមានការខំប្រឹងខ្នះខ្នែងជាអចិន្ត្រៃយ៍ ក្នុងការពុះពារយកជ័យជំនះ ទៅលើការលំបាកលំបិនសព្វបែបយ៉ាង ដែលគេតែងតែពើបប្រទះក្នុងពេលដែលគេយកច្បាប់វិន័យទៅ អនុវត្ត ព្រោះគេដឹងថា បទបញ្ជាទាំងឡាយ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ខាងក្រោមនេះជាគោលសំខាន់ៗ និងយ៉ាងចាំបាច់បំផុត ដែលអង្គការសហប្រជាជាតិ បានទទួលស្គាល់ និងបានដាក់កំរិតអោយ ។

៣.ម្យ៉ាងវិញទៀត បទបញ្ញាទាំងនេះ គ្របដណ្តប់ទៅលើវិស័យមួយ ដែលគំនិតថ្មីៗ (ក្នុងការគ្រប់គ្រងអ្នកទោសនេះ) កំពុងតែរីកចំរើនជាលំដាប់។ មិនត្រូវគិតគោរពតាមបទបញ្ញាទាំងនេះ)ហើយឈប់គិតទៅដល់ការស្រាវជ្រាវពិសោធន៍ អោយដឹងថាតើ បទបញ្ញាទាំងនេះចុះសំរុងជាមួយគោលការណ៍នៃការថែទាំអ្នកទោសដែរឬទេបើបោះបង់ចោលនូវការរិះរកមធ្យាបាយនានាសំរាប់ ឆ្លើយតបទៅនឹងគោលបំណងថ្មីៗទៀត ដែលអាចកើតចេញអំពីបទបញ្ញាទាំងមូលនេះ ។ ដើម្បីអោយទីបញ្ជាការអភិបាលពន្ធនាគារ (គុក) យល់ស្រប និងអនុញ្ញាតអោយបង្កើត ឬបន្ថែមគំនិតថ្មីទៅលើបទបញ្ញានោះ គេត្រូវតែបញ្ជាក់បងាញនូវហេតុផល ឬមូលហេតុអោយបានប្រាកដប្រជា ។

៤. (១) ភាគទីមួយនៃច្បាប់វិន័យនេះ ជាច្បាប់ទូទៅសំរាប់ប្រើប្រាស់ក្នុងការគ្រប់គ្រងមន្ទីរឃុំឃាំងទាំងមូល។ ច្បាប់នេះ អាចប្រើបានចំពោះអ្នកជាប់ទោសគ្រប់ប្រភេទ, ទោសបទឧក្រិដ្ឋ ឬបទស៊ីវិល, អ្នកទោសដែលពុំទាន់បានទទួលការកាត់ទោស ពីតុលាការ ឬអ្នកទោសដែលតុលាការកាត់ទោសហើយ ហើយនិងអ្នកមានទោសស្រាលៗដែលប្រព្រឹត្តអំពើដែលធ្វើអោយរំខានដល់សន្តិសុខក្នុងសង្គម ឬអ្នកទោសដែលចៅក្រមដាក់បញ្ជាអោយកសាងខ្លួន ។

(២) ភាគទីពីរគឺជាច្បាប់វិន័យសំរាប់តែប្រើទៅលើប្រភេទពិសេស ដែលគេចែកចេញជាជំពូកផ្សេងៗគា។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ, ច្បាប់សំរាប់ជំពូក (ក) ដែលសំរាប់ប្រើចំពោះអ្នក ទោសដែលតុលាការកាត់ទោសហើយ ក៏អាចយក ទៅប្រើលើអ្នកទោសជំពូក ខ, គ, និង ឃ បានដែរ កុំឲ្យតែមានទំនាស់ជាមួយនឹងច្បាប់សំរាប់គ្រប់គ្រងអ្នកទោសទាំងនេះ (ជំពូក ខ, គ, និង ឃ ) ។ ការ យកច្បាប់សំរាប់ក្រុមអ្នកទោសជំពូក (ក) ទៅប្រើចំពោះអ្នកទោសជំពូកទៀត ត្រូវសំដៅទៅលើ គោលបំណងសំរាប់ថែរក្សាការពារផលប្រយោជន៍ពួកទាំងនេះ ។

៥. (១) ច្បាប់វិន័យទាំងនេះមិនមែនប្រាថ្នាដាក់កំរិត អោយយកទៅប្រើនៅមន្ទីរឃុំឃាំងក្មេងៗ ដូចជាមន្ទីរឃុំឃាំង ឈ្មោះ (ប៊ិកស្តុល) ឬសាលាសំរាប់អប់រំកសាងខ្លួនពួកក្មេងៗនោះទេ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

។ ប៉ុន្តែតាមធម្មតា ច្បាប់វិន័យនៅក្នុងភាគទីមួយ មានគុណភាពល្អគ្រប់គ្រាន់អាចយកទៅប្រើបាន នៅក្នុងមន្ទីរឃុំ ឃាំងសំរាប់ពួកក្មេងៗនេះ ។

(២) ជំពូកអ្នកទោសក្មេងៗ គឺដៅទៅលើពួកអ្នកទោសក្មេងៗទាំងអស់ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ តុលាការសំរាប់ក្មេងៗ។ តាមទម្លាប់, ពួកក្មេងៗទាំងនេះពុំត្រូវកាត់ទោសដាក់គុក ឡើយ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## ជំពូកទី ១

## ច្បាប់វិន័យសំរាប់ការអនុវត្តជាទូទៅ

## គោលការណ៍ជាមូលដ្ឋាន

៦. (១) បទបញ្ញត្តដូចតទៅនេះ ត្រូវយកទៅអនុវត្តន៍ដោយមិនឲ្យមានលំអៀងឡើយ ។ មិនត្រូវឲ្យមានការប្រកាន់ពូជសាសន៍, ពណ៌សំបុរ, ភេទ, ភាសា, សាសនា, មតិនយោបាយ ឬមតិដទៃៗទៀត, ដើមកំណើតជាតិ ឬសង្គម, ទ្រព្យសម្បត្តិ, ស្ថានភាពកំណើត បស្ថានភាពដទៃៗទៀតឡើយ ។

(២) ប្រ៉ាងវិញទៀតជាការចាំបាច់ត្រូវតែគោរពដល់ជំនឿសាសនានិងសីលធម៌របស់ក្រុមដែលអ្នកទោសមាន ។

៧. (១) នៅគ្រប់ទីកន្លែងដែលយកមនុស្សទៅដាក់គុក ត្រូវតែមានបញ្ជីចុះឈ្មោះដោយមាន លេខទំព័រ ដែលក្នុងនោះ អ្នកទោសម្នាក់ៗត្រូវបានទទួលនូវៈ

ក. ពត៌មានស្តីពីអត្តសញ្ញាណរបស់គាត់

ខ. ហេតុផលនានាសំរាប់ការជាប់ឃុំឃាំងរបស់គាត់ និងអាជ្ញាធរ

គ. ថ្ងៃ និងម៉ោងនៃការទទួល "ដាក់គុក" និងការដោះលែង "ចេញពីគុក" ។

(២) គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងមន្ទីរឃុំឃាំងដោយគ្មានលិខិតបញ្ជា "ដីកា" ឲ្យឃុំឃាំងត្រឹមត្រូវដែលសេចក្តី លំអិតនៃលិខិតបញ្ជានោះត្រូវបានចុះ "កត់ត្រា" ក្នុងបញ្ជីច្បាស់លាស់ឡើយ ។

## ការបែងចែកអ្នកទោសតាមជំពូក

៨. ជំពូកអ្នកទោសខុសៗគ្នា ត្រូវឃុំក្នុងមន្ទីរឃុំឃាំង ឬផ្នែកនៃមន្ទីរឃុំឃាំងដាច់ដោយឡែកៗពី គ្នាដោយយោងទៅតាម ភេទ, អាយុ, ប្រវត្តិបទឧក្រិដ្ឋ, ហេតុផលខាងផ្លូវច្បាប់សំរាប់ការឃុំខ្លួនរបស់គេ ព្រមទាំងសេចក្តីចាំបាច់នានា នៃការ ប្រព្រឹត្តចំពោះ ពួកគេ ។

ក. អ្នកទោសប្រុសនិងអ្នកទោសស្រី ត្រូវដាក់ឃុំដាច់ដោយឡែក និងអោយបានឆ្ងាយពីគ្នា តាមលទ្ធភាពដែលអាចធ្វើទៅបាន។ ចំពោះមន្ទីរឃុំឃាំងដែលទទួលយកទាំងអ្នកទោសប្រុស និងអ្នកទោសស្រីនោះ បរិវេណសំរាប់ដាក់អ្នកទោសស្រីត្រូវតែនៅដាច់ដោយឡែកពីគ្នាជាដាច់ខាត ។

ខ. ពិរុទ្ធជន ត្រូវតែដាក់ឲ្យនៅដាច់ដោយឡែកពីទណ្ឌិត


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

គ.អ្នកជាប់គុកដោយសារជំពាក់បំណុលគេ និងជាប់ដោយសាររឿងស៊ីវិល "រដ្ឋប្បវេណី" ត្រូវដាក់អោយដាច់ឡែកពីអ្នកជាប់គុក ដោយសារហេតុផលបទល្មើសព្រហ្មទណ្ឌ ។

ឃ.អ្នកទោសក្មេងៗ "យុវទោសករ" ត្រូវដាក់ឲ្យដាច់ឡែកពីអ្នកទោសពេញវ័យ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## ទីកន្លែងសំរាប់អ្នកទោសស្នាក់នៅ

៩. (១) ប្រសិនបើវិន័យចែងថា អ្នកទោសអាចមានបន្ទប់ដេកម្នាក់មួយរៀងៗខ្លួន អ្នកទោសម្នាក់ៗមានសិទ្ធិដេកក្នុង បន្ទប់មួយតែម្នាក់ឯងគត់។ ប៉ុន្តែ ដោយមូលហេតុពិសេសខ្លះ ដូចជាពេលខ្លះ មានអ្នកទោសច្រើនហួសចំណុះជាដើម អភិបាលប្រចាំពន្ធនាគារកណ្តាល មាន ភារកិច្ចចាំបាច់ត្រូវតែដោះ ស្រាយរកកន្លែងអោយអ្នកទោសថ្មីៗស្នាក់នៅ។ ប្រសិនបើមានការ ប៉ះទង្គិចដល់ បទវិន័យខាងលើនេះ បន្តិចបន្តួចក៏មិនជាការអ្វីដែរ។ ប៉ុន្តែបើជៀសវាងបាន គួរ កុំដាក់អ្នកទោសពីរនាក់ឲ្យនៅដេកក្នុងទ្រុង ឬបន្ទប់ មួយជាមួយគ្នា ។

(២) ប្រសិនបើអ្នកទោសដេកក្នុងសាលធំៗជាមួយគ្នា គេត្រូវជ្រើសយកតែអ្នកទោស ប្រភេទណាដែលអាចរស់នៅ ជាមួយគ្នាបាន ឲ្យនៅដេកក្នុងបន្ទប់ជាមួយគ្នាហើយត្រូវអោយមាន ការត្រួត មើលឲ្យបានទៀងទាត់ជិតដល់នៅពេលយប់ៗ។

១០. គ្រប់កន្លែងស្នាក់នៅដែលប្រើសំរាប់ដាក់អ្នកទោស និងជាពិសេសកន្លែងដេកទាំងអស់ ត្រូវ ស្របទៅតាមតម្រូវការ គ្រប់យ៉ាងខាងសុខភាព ពោលគឺយកចិត្តទុកដាក់ទៅលើលក្ខណៈ ធាតុអាកាស និងជាពិសេសគឺត្រូវមានខ្យល់ដកដង្ហើមគ្រប់គ្រាន់, មានទំហំសមល្មម, មានពន្លឺ គ្រប់គ្រាន់, កំដៅគ្រប់គ្រាន់ (សំរាប់រដូវរងារ) និងត្រូវមានបង្អួចទ្វារធំទូលាយសំរាប់ឲ្យខ្យល់បក់ ចេញចូលគ្រប់គ្រាន់ ។

១១. នៅគ្រប់ទីកន្លែងណាដែលគេតម្រូវឲ្យអ្នកទោសនៅផង ហើយធ្វើការផង ត្រូវមានបែប ផែនដូចខាងក្រោមនេះ៖

(ក) ត្រូវមានបង្អួចទូលំទូលាយ ដើម្បីអោយអ្នកទោសអាចធ្វើការ ឬអានសៀវភៅបាន ដោយពន្លឺ ថ្ងៃ ហើយឲ្យមានច្រកចំហធំៗ ដើម្បីអោយខ្យល់បក់បានគ្រប់គ្រាន់ ទោះជាមានឬគ្មាន កង្ហារបក់ ខ្យល់ក៏ដោយ។

(ខ) ភ្លើងអំពូល ឬភ្លើងអគ្គិសនី ត្រូវអោយមានគ្រប់គ្រាន់និងត្រឹមត្រូវ ដើម្បីការពារ កុំអោយខូចភ្នែកអ្នកទោសនៅ ពេលអានសៀវភៅ ឬនៅពេលធ្វើការ ។

១២. បង្គន់ត្រូវឲ្យមានគ្រប់គ្រាន់សំរាប់សេចក្តីត្រូវការរបស់អ្នកទោសគ្រប់ពេលវេលា ហើយ ត្រូវអោយមានការស្អាតបាតសមរម្យផងដែរ ។


រក្សាសិទ្ធិ © ២០០៩ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

១៣.ត្រូវមានបន្ទប់ទឹកគ្រប់គ្រាន់។ ប្រដាប់ប្រើប្រាស់ក្នុងបន្ទប់ទឹកក៏ត្រូវឲ្យមានគ្រប់គ្រាន់។ ត្រូវឲ្យមានទឹកត្រជាក់ ឬក្តៅ យោងទៅតាមធាតុអាកាសខាងក្រៅ (បើខែរងារត្រូវអោយមានទឹកក្តៅ) ត្រូវមានទឹកគ្រប់គ្រាន់សំរាប់សេចក្តីត្រូវការ ច្រើនឬតិចរបស់អ្នកទោស ដោយយោងទៅតាមអនាម័យ ទូទៅប្រចាំរដូវកាល បតំបន់ភូមិសាស្ត្រ។

១៤.គ្រប់ផ្នែកនៃ មន្ទីរឃុំឃាំង ដែលសំរាប់ឲ្យអ្នកទោសប្រើប្រាស់ជានិច្ចជាកាលត្រូវថែទាំ, សំអាតឲ្យបានត្រឹមត្រូវនិង យ៉ាងហ្មត់ចត់គ្រប់ពេលវេលា ។

## អនាម័យប្រចាំកាយ

១៥.អ្នកទោសត្រូវរក្សារាងកាយបានស្អាតបាត។ ហេតុនេះ ពួកគេត្រូវតែផ្តល់ឲ្យនូវទឹកស្អាត ព្រមទាំងគ្រឿងបរិក្ខា ប្រើប្រាស់ក្នុងបន្ទប់ទឹកផ្សេងៗដែលជាការចាំបាច់សំរាប់សុខភាព និងភាពស្អាត ។

១៦.វិន័យចែងថា អ្នកទោសអាចថែរក្សាខ្លួនឲ្យមានសភាពសមរម្យជាមនុស្សដូចគេទៀត។ ក្នុងន័យនេះ មន្ទីរឃុំឃាំង ត្រូវតែមានជាងកាត់សក់សំរាប់សេចក្តីត្រូវការរបស់អ្នកទោស។ ត្រូវផ្តល់ប្រដាប់កោរពុកមាត់ឲ្យអ្នកទោសឲ្យបានទៀងទាត់ ។

## ការស្លៀកពាក់និងការដេក

១៧. (១) រាល់អ្នកទោសណា ដែលគេមិនអនុញ្ញាតិឲ្យស្លៀពាក់សំលៀកបំពាក់ផ្ទាល់ខ្លួនរបស់គេទេ នោះពួកគេត្រូវតែបានគេផ្តល់ឲ្យនូវសំលៀកបំពាក់ណាមួយ ដែលសមស្របទៅនឹងធាតុអាកាស និងគ្រប់គ្រាន់ដើម្បីរក្សាគេឲ្យមានសុខភាពល្អ ។ សំលៀកបំពាក់នេះទៀតក៏មិនត្រូវធ្វើឲ្យមានលក្ខណៈ បន្ទាបមន្ថោក ឬក៏មើលងាយមើលថោកពីអ្នកដទៃឡើយ ។

(២) សំលៀកបំពាក់ទាំងអស់ត្រូវតែឲ្យស្អាតហើយឲ្យមានលក្ខណៈសមរម្យជានិច្ច ។សំលៀកបំពាក់ទ្រនាប់ ត្រូវផ្លាស់ប្តូរនិងបោកសំអាតឲ្យបានញឹកញាប់តាមការចាំបាច់ ដើម្បីរក្សាអនាម័យប្រចាំកាយ ។

(៣) តាមកាលៈទេសៈពិសេសខ្លះ នៅពេលណាគេយកអ្នកទោសចេញទៅក្រៅមន្ទីរឃុំឃាំងក្នុងគោលបំណងណាមួយដែលមានការអនុញ្ញាតតាមច្បាប់ អ្នកទោសត្រូវតែបានអនុញ្ញាតិអោយ ស្លៀកពាក់សំលៀកបំពាក់ផ្ទាល់ខ្លួនរបស់គេ ឬក៏សំលៀកបំពាក់ផ្សេងៗ ដែលពុំមានលក្ខណៈលេចធ្លោ ខុសគេខុសឯងពេក ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

១៨. ប្រសិនបើគេអនុញ្ញាតឲ្យអ្នកទោសស្លៀកពាក់ខោអាវផ្ទាល់ខ្លួននៅក្នុងគុកអាជ្ញាធរត្រូវធានាថា ខោអាវទាំងនេះ ត្រូវរក្សាឲ្យស្អាតបាត ហើយមានគុណភាពល្អសមល្មមប្រើបានជានិច្ច។ ចំណាត់ការបែបនេះត្រូវផ្តើមធ្វើចាប់តាំងពីថ្ងៃដែលអ្នកទោសចូលមកដល់មន្ទីរឃុំឃាំងម្លេះ ។

១៩. យោងទៅតាមកំរឹតរស់នៅ (សំរាប់អ្នកទោស) ប្រចាំតំបន់ឬប្រចាំរដ្ឋទាំងមូល អ្នកទោសគ្រប់ៗរូបត្រូវតែមាន គ្រែដេកម្នាក់មួយ, ភួយ, ខ្នើយ, ហើយនឹងកំរាលពូកដោយឡែកពីអ្នកទោសទៀត ហើយត្រូវឲ្យស្អាត។ ត្រូវផ្លាស់ប្តូរកំរាល ស្រោមខ្នើយនិងភួយឲ្យបានញឹកញយដើម្បីរក្សាភាព ស្អាតបាត ។

## ម្ហូបអាហារ

២០. (១) អ្នកទោសគ្រប់រូប ត្រូវតែបានទទួលម្ហូបអាហារ ដែលផ្តល់ឲ្យដោយរដ្ឋតាមពេលម៉ោងធម្មតា ។ ម្ហូបអាហារនោះ ត្រូវមានគុណភាព និងជីវជាតិអាហារគ្រប់គ្រាន់ដើម្បីសុខភាពនិងកម្លាំងពលំ ដែលមានការដាំស្លនិងបំរើដោយយក ចិត្តទុកដាក់ ។

(២) ទឹកសំរាប់ផឹកត្រូវឲ្យមានគ្រប់គ្រាន់សំរាប់នៅពេលណាអ្នកទោសត្រូវការ ។

## ការហាត់ប្រាណនិងលេងកីឡា

២១. (១) អ្នកទោសគ្រប់រូប ដែលមិនបានចេញទៅធ្វើការនៅខាងក្រៅមន្ទីរឃុំឃាំងទេនោះ ត្រូវមានឱកាសហាត់ប្រាណ នៅក្នុងទីធ្លាស្រឡះយ៉ាងតិចមួយម៉ោងជារៀងរាល់ថ្ងៃប្រសិនបើធាតុអាកាសអនុញ្ញាតិ ។

(២) អ្នកទោសក្មេងៗ "យុវទោសករ" និងអ្នកទោសដែលមានអាយុមិនចាស់ជរាពេក ហើយដែលនៅមានរាងកាយមាំមួនល្អ ត្រូវឲ្យមានការហ្វឹកហាត់ខាងកាយវប្បកម្ម និងខាងការកំសាន្ត ផងនៅក្នុងពេលហាត់ប្រាណ។ ក្នុងន័យនេះដែរមន្ទីរ ត្រូវតែផ្តល់ទីកន្លែង, តម្លើងនិងផ្តល់សំភារៈផ្សេងៗ។

## ការព្យាបាលជម្ងឺ

២២. (១) នៅគ្រប់មន្ទីរឃុំឃាំង យ៉ាងហោចណាស់ក៏ត្រូវមានមន្ត្រីពេទ្យពេញលក្ខណៈម្នាក់ដែលជាអ្នកមានចំណេះខះៗ ខាងចិត្តសាស្ត្រផង។ សេវាកម្មសុខាភិបាលត្រូវរៀបចំឲ្យមានទំនាក់ទំនង យ៉ាងជិតស្និទជាមួយនឹងរដ្ឋបាលសុខាភិបាលទូទៅ របស់សហគមន៍ ឬជាតិ។ គេត្រូវ


រក្សាសិទ្ធ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

រាប់បញ្ចូលទាំងសេវា កម្មចិត្តសាស្ត្រផងដែរ ដើម្បីធ្វើរោគវិនិច្ឆ័យ និងព្យាបាលនូវបញ្ហាខុសប្រក្រតីនៃស្ថានភាព “បជំងឺ” ផ្លូវចិត្តតាមករណីសមរម្យ ។

(២) អ្នកទោសណាឈឺដែលត្រូវការព្យាបាលពីគ្រូពេទ្យជំនាញ ត្រូវតែបញ្ជូនទៅកាន់ស្ថាប័នជំនាញ ឬក៏ទៅមន្ទីរពេទ្យ ស៊ីវិល។ នៅទីណាដែលមានមន្ទីរពេទ្យនៅក្នុងមន្ទីរឃុំឃាំងទាំងឧបករណ៍ប្រើប្រាស់ទាំងថ្នាំសង្កូវ ត្រូវឲ្យបានសមរម្យ សំរាប់ការថែរក្សា និងការព្យាបាលអ្នកទោសដែលឈឺ ហើយត្រូវមានបុគ្គលិកដែលមានការហ្វឹកហ្វឺនត្រឹមត្រូវក្នុងមុខវិជ្ជានេះ ។

(៣) ត្រូវតែមានពេទ្យធ្មេញដែលពេញលក្ខណៈម្នាក់សំរាប់ថែរក្សាធ្មេញអោយអ្នកទោសគ្រប់ៗគា។

២៣. (១) នៅក្នុងមន្ទីរឃុំឃាំងរបស់អ្នកទោសស្រីៗ ត្រូវឲ្យមានការឧបត្ថមពិសេសសំរាប់ការថែរក្សា និងព្យាបាល ខ្លួននៅពេលមុននិងក្រោយការសំរាលកូន។ ត្រូវតែអនុញ្ញាតឲ្យអ្នកទោសបាន ចេញទៅកើតកូនក្រៅគុក។ ប៉ុន្តែបើសិនជាមានកើតកូននៅក្នុងគុក មិនត្រូវចុះសំបុត្រកំណើតថាទារក នោះកើតនៅក្នុងគុកទេ ។

(២) នៅក្នុងមន្ទីរឃុំឃាំងណាដែលអនុញ្ញាតឲ្យម្តាយបីបាច់ថែរក្សាកូនដោយខ្លួនឯង ក៏ត្រូវឲ្យមានក្រុមអ្នកថែរក្សាទារក (ឬក្មេងៗ) សំរាប់កាលៈទេសៈណាដែលម្តាយមិននៅ ។

២៤. គ្រូពេទ្យត្រូវពិនិត្យអ្នកទោសគ្រប់រូបឲ្យបានឆាប់បំផុតបន្ទាប់ពីទទួលយកអ្នកទោសមកឃុំឃាំង និងត្រូវពិនិត្យនៅពេលក្រោយៗទៀតតាមការចាំបាច់ ដើម្បីពិនិត្យរកមើលជម្ងឺផ្លូវកាយ ឬផ្លូវចិត្ត និងចាត់វិធានការចាំបាច់ដូចជា ដាក់អ្នកទោសណា ដែលគេសង្ស័យថាមានកើតជម្ងឺឆ្លងឬមានលក្ខណៈឆ្លងឲ្យនៅដាច់ដោយឡែកពីគេ ឬដើម្បីធ្វើការកត់សំគាល់អំពីលក្ខណៈមិនគ្រប់គ្រាន់ខាងផ្លូវកាយឬផ្លូវចិត្ត ដែលអាចធ្វើឲ្យប៉ះពាល់ដល់ការកសាងខ្លួន និងដើម្បីកំណត់ទៅលើសមតភាពរាងកាយរបស់អ្នក ទោសសំរាប់អោយទៅធ្វើការ ។

២៥. (១) ភ្នាក់ងារសុខាភិបាល (ពេទ្យ) ត្រូវយកចិត្តទុកដាក់ថែរក្សាសុខភាពអ្នកទោសទាំងវិស័យផ្លូវចិត្ត និងផ្លូវកាយ ត្រូវពិនិត្យ ព្យាបាលជម្ងឺអ្នកទោសរាល់ៗថ្ងៃ ត្រូវជួបប្រាស្រ័យជាមួយអ្នក ទោសទាំងឡាយណាដែលសំអាងថាខ្លួនមានជម្ងឺ ហើយ ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះអ្នកជម្ងឺណា ដែលក្រសួងតម្រូវអោយ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(២) ភ្នាក់ងារពេទ្យត្រូវរាយការណ៍ជំរាបទៅលោកនាយកពន្ធនាគារភ្លាម កាលណាពេទ្យយល់ឃើញថាការឃុំឃាំងក្នុងគុកតទៅទៀត ឬស្ថានភាពនៃការឃុំឃាំងបែបនេះ អាចធ្វើឲ្យខូចខាតដល់ សុខភាពខាងផ្លូវកាយ ឬសុខភាពខាងផ្លូវចិត្ត របស់អ្នកទោសណាមាក់ ។

២៦. (១) ភ្នាក់ងារសុខាភិបាល (ពេទ្យ) មានភារកិច្ចពិនិត្យនិងឲ្យដំបូន្មានទៅចាងហ្វាងគុកឲ្យបានទៀងទាត់តាមកាល កំណត់អំពីប្រការទាំងឡាយខាងក្រោមនេះ

(ក) ចំនួននិងគុណភាពអាហារ ការចំអិននិងការចែកម្ហូបអាហារឲ្យអ្នកទោស ។

(ខ) អនាម័យនិងការសំអាតមន្ទីរឃុំឃាំង អនាម័យនិងការសំអាតខ្លួនប្រាណនៃពួកអ្នកទោស។

(គ) ការសំអាត ការផ្តល់កំដៅ ការផ្តល់ពន្លឺ ហើយនិងការធ្វើឲ្យមានខ្យល់អាកាសចេញចូលក្នុង មន្ទីរឃុំឃាំង ។

(ឃ) ការប្រតិបត្តិតាមបទបញ្ជាដែលចែងអំពីការហាត់ប្រាណ និងការលេងកីឡា ប្រសិនបើនៅក្នុងគុកនេះគ្មានបុគ្គលិក បច្ចេកទេសទទួលបន្ទុកខាងសកម្មភាពទាំងពីរខាងលើទេ ។

(២) នាយកមន្ទីរឃុំឃាំងត្រូវពិនិត្យយ៉ាងយកចិត្តទុកដាក់នូវសេចក្តីរាយការណ៍ ហើយនឹងពាក្យណែនាំដែល លោកគ្រូពេទ្យបានធ្វើ ដោយយោងទៅតាមបទបញ្ជាក្នុងវគ្គ (២) នៃមាត្រា ២៥ ហើយនឹងមាត្រា ២៦ ។ ប្រសិនបើមានការស្របមតិគ្នា នាយកមន្ទីរត្រូវចាត់វិធានការធ្វើតាមពាក្យណែនាំទាំងនេះភ្លាម។ ប្រសិនបើមិនស្របតាមពាក្យណែនាំនេះទេ ឬប្រសិនបើ ពាក្យណែនាំនេះមានទំហំ ការធំហួសពីសមត្ថកិច្ចរបស់ខ្លួន នាយកមន្ទីរត្រូវធ្វើសេចក្តីរាយការណ៍មួយភ្ជាប់ជាមួយនឹងពាក្យណែនាំ របស់គ្រូពេទ្យ ហើយបញ្ជូនទៅអាជ្ញាធរថ្នាក់លើភាម ។

## វិន័យនិងទណ្ឌកម្ម

២៧. វិន័យនិងបទបញ្ជា នៅក្នុងគុកត្រូវអនុវត្តឲ្យបានម៉ឺងម៉ាត់។ ប៉ុន្តែពុំត្រូវឲ្យមានការហាមប្រាមច្រើនហួសអំពីការ ចាំបាច់សំរាប់រក្សាសន្តិសុខក្នុងគុក ហើយនឹងឲ្យប្រកបដោយជីវិតដ៏មានរបៀបរៀបរយល្អប្រពៃក្នុងសហគមន៍ ។

២៨. (១) ក្នុងសេវាកម្មរបស់មន្ទីរឃុំឃាំង មិនត្រូវជួលអ្នកទោសណាម្នាក់ឲ្យបំពេញមុខងារមួយ ក្នុងសមត្ថកិច្ច រក្សាបទវិន័យឡើយ ។


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(២) បទវិន័យនេះមិនត្រូវបង្អាក់ដល់កិច្ចដំណើរការល្អនៃប្រព័ន្ធនានាដែលផ្អែកលើការគ្រប់គ្រងដោយខ្លួនឯង ដែលស្ថិតនៅក្រោមសកម្មភាពសង្គម, អប់រំ ឬកីឡា ឬការទទួលខុសត្រូវណា មួយដែលគេបានប្រគល់ឲ្យទៅអ្នកទោសណាដែល ចងក្រងជាក្រុម, ជាពួក ដើម្បីគោលបំណងនៃការ ប្រព្រឹត្តនេះឡើយ ។ ក៏ប៉ុន្តែ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ។

២៩.ប្រការខាងក្រោមនេះ ត្រូវស្ថិតនៅក្រោមការសំរេចនៃច្បាប់រដ្ឋ ឬ តាមបទបញ្ជានៃអាជ្ញាធរមានសមត្ថកិច្ចផ្នែក អភិបាល ។

(ក) ការប្រព្រឹត្តខុសនឹងបទវិន័យ

(ខ) ប្រភេទនិងរយៈពេលនៃការដាក់ទណ្ឌកម្ម ប្រសិនបើមាន

(គ) អាជ្ញាធរមានសមត្ថកិច្ចណាដែលមានភារៈដាក់ទណ្ឌកម្ម ។

៣០. (១) មិនត្រូវដាក់ទណ្ឌកម្មអ្នកទោសឡើយ លើកលែងតែទណ្ឌកម្មដែលអនុលោមទៅតាមល័ក្ខខ័ណ្ឌនៃច្បាប់ និង បទវិន័យដូចចែងខាងលើ ។ ហើយមិនត្រូវធ្វើទណ្ឌកម្មពីរដងទៅលើអ្នកទោសដែលប្រព្រឹត្តកំហុសតែម្តងឡើយ ។

(២) ពុំត្រូវដាក់ទណ្ឌកម្មអ្នកទោសជាដាច់ខាតប្រសិនបើគេពុំទាន់បានប្រាប់សាម៉ីខ្លួនឲ្យដឹងច្បាស់អំពីកំហុស ដែលគេចោទថាខ្លួនបានប្រព្រឹត្ត និងមិនបានទុកលទ្ធភាពឲ្យបានសមរម្យសំរាប់សាម៉ីខ្លួនធ្វើការការពារខ្លួន។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវធ្វើការពិនិត្យពិច្ច័យហេតុការណ៍នេះឲ្យបានសព្វគ្រប់

(៣) នៅក្នុងករណីចាំបាច់ខ្លះ ត្រូវតែអនុញ្ញាត្តឲ្យអ្នកទោសធ្វើការការពារខ្លួនតាមរយៈអ្នកបកប្រែភាសា (ពេល អ្នកទោសមិនចេះស្តាប់និងចេះនិយាយភាសាដែលគេប្រើនៅសាលាកាត់ក្តី ឬតុលាការ។

៣១.ទណ្ឌកម្មលើរាងកាយ, ទណ្ឌកម្មដោយដាក់ក្នុងគុកងងឹត និងទណ្ឌកម្មទាំងឡាយណាដែលឃោរឃៅ, អមនុស្សធម៌ ឬបន្ទាបបន្ថោកនាំឲ្យបាត់បង់តម្លៃមនុស្ស ដែលប្រើជាទណ្ឌកម្មសំរាប់ការដែលប្រព្រឹត្តិល្មើសនឹងបទវិន័យរបស់មន្ទីរឃុំឃាំងនោះ ត្រូវបានហាមឃាត់ជាដាច់ខាត ។

៣២. (១) ទណ្ឌកម្មដោយការដាក់ឃុំឃាំងក្នុងបន្ទប់ដាច់តែម្នាក់ឯង ឬទណ្ឌកម្មដោយការកាត់ បន្ថយអាហារត្រូវបាន ហាមមិនអោយធ្វើឡើយ ប្រសិនបើគ្រូពេទ្យមិនបានពិនិត្យ


រក្សាសិទ្ធិ © ២០០៩ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

អ្នកទោស ហើយ បញ្ជាក់ជាលាយល័ក្ខអក្សរថា អ្នកទោសមានសុខភាព គ្រប់គ្រាន់អាចទទួលទណ្ឌកម្មបែបនេះទេនោះ ។

(២) បំរាមខាងលើ ក៏ហាមចំពោះទណ្ឌកម្មទាំងឡាយណាផ្សេងទៀត ដែលអាចនាំឲ្យប៉ះពាល់ដល់សុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់អ្នកទោស។ គ្មានករណីណាមួយអាចឲ្យទណ្ឌកម្មនេះផ្ទុយ ឬ ប្រាស់ចាកពីគោលការណ៍ដែលមានចែងនៅក្នុង បទបញ្ញាត្តិទី ៣១ ដាច់ខាត ។

(៣) គ្រូពេទ្យត្រូវចុះពិនិត្យអ្នកទោសដែលត្រូវទទួលទណ្ឌកម្មបែបនេះឲ្យបានរាល់ថ្ងៃ និងត្រូវផ្តល់ដំបូន្មានដល់ នាយកមន្ទីរឃុំឃាំង ប្រសិនបើគ្រូពេទ្យយល់ថា ការបញ្ចប់ការផ្លាស់ប្តូរទណ្ឌកម្ម វាជាការចាំបាច់សំរាប់ហេតុផល សុខភាព ផ្លូវកាយ ឬ ផ្លូវចិត្ត។

## គ្រឿងប្រដាប់សំរាប់ឃុំខ្លួនអ្នកទោស

៣៣. ឧបករណ៍ទប់ទល់នឹងអ្នកទោស ដូចជា ខ្នោះដៃ ច្រវ៉ាក់ ដែកឃ្នាប និងអាវធំ (គឺអាវធំម្យ៉ាងដែលរឹង កាលណា ពាក់ឲ្យអ្នកទោសហើយ អ្នកទោសមិនអាចកំរើកខ្លួនបានឡើយ ) មិនត្រូវប្រើ ប្រាស់ជាការដាក់ទណ្ឌកម្មឡើយ ។ លើសពីនេះទៀត ច្រវ៉ាក់ ឬដែកឃ្នាប មិនត្រូវប្រើប្រាស់ជាការទប់ទល់ឡើយ។ ឧបករណ៍ទប់ទល់នឹងអ្នកទោសផ្សេងៗទៀតក៏មិនត្រូវប្រើឡើយ លើកលែងតែក្នុងកាលៈទេសៈដូចខាងក្រោមនេះ៖

(ក) ប្រើការពារកុំឲ្យអ្នកទោសរត់ក្នុងពេលបញ្ជូនអ្នកទោសពីកន្លែងមួយទៅកន្លែងមួយទៀត ហើយត្រូវដោះវិញភ្លាម នៅពេលណាអ្នកទោសនៅចំពោះមុខអាជ្ញាធរតុលាការ ឬ រដ្ឋបាលណាមួយ ហើយនោះ ។

(ខ) ប្រើដើម្បីហេតុផលខាងពេទ្យ តាមការណែនាំរបស់គ្រូពេទ្យ ។

(គ) ប្រើតាមបញ្ជារបស់នាយកមន្ទីរឃុំឃាំង ដើម្បីការពារកុំឲ្យអ្នកទោសនោះបង្ករបួសស្នាមដល់ខ្លួនឯង ឬដល់អ្នកដទៃ ឬដើម្បីការពារកុំអោយអ្នកទោសបង្ករការខូចខាតដល់ទ្រព្យសម្បត្តិផ្សេងៗប្រសិនបើវិធីផ្សេងៗទៀតត្រូវបរាជ័យ។ ក្នុងខណៈនោះដែរ នាយកមន្ទីរឃុំឃាំងត្រូវពិគ្រោះជាមួយគ្រូពេទ្យជាបន្ទាន់ ហើយរាយការណ៍ទៅជូនអាជ្ញាធររដ្ឋបាលថ្នាក់លើ ។

៣៤. លំនាំនិងរបៀបបែបបទនៃការប្រើគ្រឿងប្រដាប់ទាំងនេះស្ថិតនៅក្រោមការសំរេចរបស់អភិបាលកណ្តាលនៃ មន្ទីរឃុំឃាំង។ គ្រឿងប្រដាប់ទាំងនេះមិនត្រូវប្រើឲ្យហួសពីពេលដែលគេបានបញ្ជាឡើយ។


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## ពត៌មានសំរាប់អ្នកទោសនិងការតវ៉ាពីសំណាក់អ្នកទោស

៣៥. (១) អ្នកទោសគ្រប់រូប ដែលទើបនឹងចូលមកដល់មន្ទីរឃុំឃាំងថ្មីៗ ត្រូវតែបានទទួលពតិមានជាលាយល័ក្ខអក្សរស្តីពីបទបញ្ជានានា ក្នុងការគ្រប់គ្រងទៅលើការប្រព្រឹត្តិចំពោះអ្នកទោស តាម ជំពូកនិមួយៗរបស់អ្នកទោស, តំរូវការខាងបទវិន័យរបស់មន្ទីរឃុំឃាំង, របៀបសាកសួរពតិមាន និងធ្វើពាក្យបណ្តឹងដែលគេអនុញ្ញាតិ ព្រមទាំងប្រការដូចនេះផ្សេងៗទៀត ដែល ជាការចាំបាច់ដើម្បីអ្នកទោសបានយល់ទាំងសិទ្ធិ ទាំងករណីកិច្ចរបស់គេ និងដើម្បីឲ្យគេសម្របសម្រួលខ្លួនទៅនឹងជីវិតរស់នៅក្នុង មន្ទីរឃុំឃាំង ។

(២) ប្រសិនបើអ្នកទោសមិនចេះអក្សរទេ ពតិមានទាំងឡាយដូចមានចែងខាងលើត្រូវយកមកនិយាយពន្យល់ ប្រាប់អ្នកទោសដោយផ្ទាល់មាត់ ។

៣៦. (១) ជារៀងរាល់ថ្ងៃ " លើកលែងតែថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យចេញ" អ្នកទោសគ្រប់ៗរូបត្រូវមានឱកាសធ្វើសំណើរ ឬពាក្យបណ្តឹងទៅនាយកមន្ទីរឃុំឃាំង ឬភ្នាក់ងារណាមួយដែលគេអនុញ្ញាតិ អោយធ្វើជាអ្នកតំណាងគាត់ ។

(២) ត្រូវផ្តល់លទ្ធភាពឲ្យអ្នកទោសអាចធ្វើសំណើឬ ពាក្យបណ្តឹងទៅលោកអធិការក្នុងកំឡុងពេលដែលលោក អធិការចុះមកពិនិត្យមន្ទីរឃុំឃាំង ។ អ្នកទោសត្រូវមានឱកាសនិយាយទៅកាន់លោកអធិការ ឬ ភ្នាក់ងារអធិការកិច្ចផ្សេងទៀត ដោយគ្មាននាយកមន្ទីរឃុំឃាំង ឬបុគ្គលិក នៃមន្ទីរឃុំ ឃាំងដ៏ទៃណាមួយជិតឡើយ។

(៣) អ្នកទោសគ្រប់រូបត្រូវតែបានការអនុញ្ញាតិឲ្យធ្វើសំណើ បពាក្យបណ្តឹងទៅរដ្ឋបាលកណ្តាលនៃមន្ទីរឃុំឃាំង,អាជ្ញាធរតុលាការ ឬអាជ្ញាធរសមស្របដ៏ទៃៗទៀត តាមរយៈភ្នាក់ងារដែលក្រសួងបានអនុញ្ញាតិ ដោយគ្មានការពិនិត្យជាប់ពិរុទ្ធ សេចក្តីនៃសំណើរ ឬពាក្យបណ្តឹងនោះ ប៉ុន្តែធ្វើយ៉ាងណាអោយតែធ្វើទៅតាមបែបបទត្រឹមត្រូវ ។

(៤) រាល់សំណើរឬពាក្យបណ្តឹងត្រូវតែបានដោះស្រាយ និងឆ្លើយតបភ្លាម ដោយគ្មានការពន្យាពេលឲ្យហួសហេតុឡើយ ប្រសិនបើសំណើរ ឬពាក្យបណ្តឹងពុំបានបង្ហាញឲ្យឃើញជាក់ស្តែងថា ជាសំណើរ ឬពាក្យបណ្តឹងរឡិបរឡប់ ឬគ្មានហេតុផល ច្បាស់លាស់ទេនោះ ។

## ការទាក់ទងជាមួយអ្នកក្រៅ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៣៧.អ្នកទោសត្រូវតែបានអនុញ្ញាតិឲ្យទាក់ទងជាមួយគ្រួសារសាច់ញាតិ និងមិត្តភក្តិដែលគេសន្មត់ថាជាមនុស្សល្អតាម កាលកំណត់ជាទៀងទាត់ ទោះតាមរយៈសំបុត្រឆ្លើយឆ្លងក្តី ឬតាមរយៈការ មកសួរសុខទុក្ខដោយផ្ទាល់ក្តី។ ការទាក់ទងជាមួយ គ្រួសារសាច់ញាតិ និងមិត្តភក្តិនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យជាចាំបាច់ ។

៣៨. (១) អ្នកទោសដែលជាជនបរទេស ត្រូវតែបានអនុញ្ញាតិតាមមធ្យោបាយណាមួយដែលសមរម្យ ដើម្បីឲ្យទាក់ទងជាមួយអ្នកតំណាងទូត ឬកុងស៊ុលប្រចាំប្រទេសរបស់គេ ។

(២) ចំពោះអ្នកទោសជាជនបរទេស ដែលគ្មានអ្នកតំណាងទូត ឬកុងស៊ុលប្រចាំនៅក្នុងប្រទេស ដែលខ្លួនជាប់ឃុំឃាំងទេនោះ ឬក៏អ្នកទោសនោះជាជនភៀសខ្លួន ឬជាជនដែលគ្មានប្រទេសពិត្របាកដ ត្រូវតែបានអនុញ្ញាតិតាមមធ្យោបាយ ណាមួយដែលសមរម្យ ដើម្បីឲ្យទាក់ទងជាមួយអ្នកតំណាងទូតនៃប្រទេស ដែលទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ពួកគេ, ឬក៏ឲ្យទាក់ទងជាមួយអាជ្ញាធរ ជាតិ ឬអន្តរជាតិណាមួយដែលគេមានភារកិច្ចការពារអ្នកទោសទាំងនោះ ។

៣៩.ត្រូវអនុញ្ញាតិឲ្យអ្នកទោសបានទទួលដំណឹង ឬពត៌មានសំខាន់ៗយ៉ាងទៀងទាត់ទាន់ពេលវេលា ពោលគឺត្រូវ អនុញ្ញតិឲ្យអ្នកទោសអានកាសែត អានសៀវភៅ ឬអត្ថបទ ដែលមន្ទីរឃុំឃាំងចេញផ្សាយ ឬស្តាប់ពត៌មានតាមវិទ្យុ ឬស្តាប់ បាឋកថា ឬសេចក្តីថ្លែងការណ៍នានាដែលរៀបចំឡើងដោយ មន្ទីរឃុំឃាំង និងមានការអនុញ្ញាតិពីក្រុមអភិបាល ។

## សៀវភៅអាន

៤០.គ្រប់មន្ទីរឃុំឃាំងទាំងអស់ត្រូវមានបណ្ណាល័យសំរាប់សេចក្តីត្រូវការរបស់អ្នកទោសគ្រប់ប្រភេទ។ ត្រូវមានសៀវភៅច្រើនបរិបូណ ទាំងសៀវភៅផ្នែកកំសាន្ត និងសៀវភៅផ្នែកសិក្សាហើយត្រូវណែនាំអ្នកទោសទាំងអស់អោយអានសៀវភៅ អោយបានច្រើនបំផុត ។

សាសនា

៤១. (១) ប្រសិនបើនៅក្នុងមន្ទីរឃុំឃាំងណាមួយមានអ្នកទោសដែលគោរពសាសនាដូចគ្នាច្រើនគ្រប់គ្រាន់ ត្រូវតែង តាំងឲ្យមានតំណាងសាសនាឬអាចារ្យម្នាក់សំរាប់សេចក្តីត្រូវការរបស់ពួកអ្នកទោសទាំងនេះ។ អ្នកតំណាងសាសនា ឬអាចារ្យ ត្រូវអោយមានចំណេះគ្រប់គ្រាន់ក្នុងវិស័យសាសនានោះ ហើយត្រូវឲ្យមានការយល់ព្រមអំពីក្រុមអភិបាលគុកផង ។ ប្រសិនបើ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

កាលៈទេសៈនៅមន្ទីរឃុំ ឃាំងអនុញ្ញាតិឲ្យការគោរពសាសនាអាចប្រព្រឹត្តិទៅបានយ៉ាងពេញលេញ ដូចអ្នកនៅក្រៅគុកដែរ ។

(២) ត្រូវអនុញ្ញាតិឲ្យអាចារ្យ ឬតំណាងសាសនាធ្វើការណែនាំអ្នកទោស (ដែលគោរពសាសនាដូចគា) ដើម្បី ជួយប្រៀនប្រដៅអ្នកទោសតាមមាគ៌ាសាសនា។ ការប្រៀនប្រដៅបែបនេះត្រូវធ្វើឡើងតាមពេលវេលាដ៏គួរសម។

(៣) មិនត្រូវហាមឃាត់ ឬខាឃាំងអ្នកទោសមិនឲ្យជួបអាចារ្យ ឬអ្នកតំណាងសាសនាឡើយ។ ផ្ទុយទៅវិញប្រសិនបើអ្នកទោសណាម្នាក់ពុំមានឆន្ទៈចង់ជួបអាចារ្យទេនោះមិនត្រូវបង្ខំជាដាច់ខាត ពោលគឺត្រូវតែគោរពតាមឆន្ទៈអ្នកទោសជានិច្ច។

៤២. បើអាចអនុវត្តទៅបាន អ្នកទោសគ្រប់រូបត្រូវតែបានអនុញ្ញាតិ ដើម្បីបំពេញនូវសេចក្តីត្រូវការនៃជីវិតខាងផ្លូវសាសនា របស់គេតាមរយៈការចូលរួមក្នុងពិធីផ្សេងៗ ដែលអនុញ្ញាតិឲ្យមាននៅក្នុងមន្ទីរឃុំឃាំង និងអនុញ្ញាតិឲ្យរក្សាទុកនូវឯកសារ ឬ សៀវភៅនានាដែលស្តីពីការប្រៀនប្រដៅ និងការ គោរពបូជាតាមមាគ៌ា នៃនិកាយសាសនារបស់គេ ។

## ការដកហូតទ្រព្យសម្បត្តិប្រចាំកាយរបស់អ្នកទោស

៤៣. (១) នៅដែលអ្នកទោសចូលមកដល់មន្ទីរឃុំឃាំងភ្លាមប្រាក់កាស, គ្រឿងអលង្ការ, សំលៀកបំពាក់ និងឥវ៉ាន់ ផ្សេងៗទៀតរបស់អ្នកទោស ដែលតាមបទបញ្ជារបស់មន្ទីរឃុំឃាំងមិនអនុញ្ញាតិឲ្យគេទុកប្រចាំកាយបាន ត្រូវដកហូតហើយរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាពមួយ ។ ត្រូវឲ្យអ្នកទោស ដែលជាម្ចាស់ឥវ៉ាន់ចុះហត្ថលេខាលើបញ្ជីឥវ៉ាន់ ដើម្បីទទួលដឹងឮ។ ត្រូវ ចាត់វិធានការចាំបាច់នានា ដើម្បីរក្សាទុកដាក់ឥវ៉ាន់ទាំងនោះឲ្យបានគង់វង់ ។

(២) ដល់ថ្ងៃដែលអ្នកទោសចេញពីមន្ទីរឃុំឃាំង ឥវ៉ាន់និងប្រាក់កាស ត្រូវតែប្រគល់ឲ្យទៅម្ចាស់គេវិញទាំងអស់ លើកលែងត្រែប្រាក់កាសទាំងនោះកន្លងមកត្រូវបានគេអនុញ្ញាតិឲ្យចាយវាយអស់ ឬទ្រព្យសម្បត្តិទាំងនោះត្រូវបានផ្ញើទៅក្រៅមន្ទីរ ឃុំឃាំង (ផ្ញើទៅឲ្យគ្រួសារសាច់ញាតិឬមិត្តភក្តិ) ឬក៏សំលៀកបំពាក់ខ្លះដែលគេយល់ឃើញថា ជាចាំបាច់ត្រូវតែកំទេចចោលដោយសារហេតុជលអនាម័យ ប្រចាំកាយ ។ អ្នកទោសត្រូវចុះហត្ថលេខាលើប័ណ្ណដែលគេប្រគល់ឥវ៉ាន់ និងប្រាក់កាសមកឲ្យគេវិញ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(៣) ប្រាក់កាស ឬឥវ៉ាន់ទាំងឡាយណា ដែលបានទទួលមកពីខាងក្រៅសំរាប់អ្នកទោស ត្រូវតែធ្វើដូចគ្នាទៅនឹង ករណីខាងលើដែរ ។

(៤) ប្រសិនបើអ្នកទោសណាម្នាក់មានថ្នាំសង្កូវជាប់មកជាមួយ គ្រូពេទ្យត្រូវសំរេចថាតើថ្នាំណាខ្លះដែលអាច អនុញ្ញាតិអោយប្រើបាន ។

## ការជូនពត៌មានអំពីសេចក្តីស្លាប់,
## ជម្ងឺជំកាត់ឬការផ្លាស់ប្តូរទីកន្លែង

៤៤. (១) កាលណាអ្នកទោសណាម្នាក់ស្លាប់ ឈឺធ្ងន់មានរបួសជាទម្ងន់ ឬក៏ត្រូវបញ្ជូនទៅមន្ទីរណាមួយ ដើម្បីព្យាបាល ជម្ងឺសសៃប្រសាទនោះ នាយកមន្ទីរឃុំឃាំង ត្រូវផ្តល់ពត៌មានជាបន្ទាន់ទៅឲ្យប្រពន្ធឬ ប្តី ឬប្រសិនបើអ្នកទោសនៅលីវទេនោះ ត្រូវ ផ្តល់ពត៌មាននេះទៅសាច់ញាតិជិតសិទ្ធបំផុតរបស់គេ និងក្នុងព្រឹត្តិការណ៍ណាក៏ដោយ ត្រូវផ្តល់ពត៌មាននេះទៅមនុស្សណាម្នាក់ដែលអ្នកទោសបានជ្រើស រើសកាលពីពេលមុន ។

(២) អ្នកទោសត្រូវបានគេផ្តល់ពត៌មានភាមៗ អំពីការស្លាប់ ឬមានជម្ងឺជាទម្ងន់នៃសាច់ញាតិជិតសិទ្ធរបស់គេ។ ក្នុងករណីដែលសាច់ញាតិជិតស្និទឈឺធ្ងន់មែនទែន នៅពេលណាកាលៈទេសៈ គួរតែបានអនុញ្ញាតិឲ្យទៅជួបអ្នកជម្ងឺជាចុងក្រោយ ទោះអនុញ្ញាតិឲ្យទៅដោយមានអ្នកយាមក្តី ឬទៅតែម្នាក់ឯងក្តី ។

(៣) អ្នកទោសគ្រប់រូប ត្រូវមានសិទ្ធិផ្តល់ពត៌មានទៅឲ្យគ្រួសារសាច់ញាតិរបស់គេបានដឹងភ្លាមៗ អំពីពត៌មាន ស្តីពីការជាប់ឃុំឃាំងរបស់គេ ឬការបញ្ជូនខ្លួនគេទៅមនីរឃុំឃាំងណាមួយផ្សេងទៀត។

## ការដឹកនាំអ្នកទោស
## (ពីកន្លែងមួយទៅកន្លែងមួយទៀត)

៤៥. (១) នៅពេលដឹកបញ្ជូនអ្នកទោសពីកន្លែងមួយទៅកន្លែងមួយទៀតនោះ ធ្វើយ៉ាងណាកុំឲ្យសាធារណជនឃើញ ច្រើនពេក ហើយវិធានការការពារសមស្របនានាត្រូវតែយកមកអនុវត្ត ដើម្បីការពារអ្នកទោសឲ្យផុតពីការត្មិះតេះដៀល ការលេចមុខជាសាធរណៈទោះជាតាមទ្រង់ទ្រាយបែបណាក៏ដោយ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(២) ការដឹកនាំដោយប្រើយាន ឬតាមមធ្យោបាយណាដែលគ្មានពន្លឺ ឬគ្មានខ្យល់បក់ចេញចូលគ្រប់គ្រាន់ ឬតាម មធ្យោបាយណាដែលធ្វើឲ្យអ្នកទោសមានការលំបាកខាងផ្លូវកាយ ត្រូវតែហាមឃាត់ជាដាច់ខាត ។

(៣) ការចំណាយចំពោះការដឹកនាំនេះត្រូវនៅក្នុងបន្ទុករបស់អាជ្ញាធរមន្ទីរឃុំឃាំង។ លក្ខណៈនៃការដឹកនាំត្រូវតែមានសមាសភាពដូចគ្នា ឬស្មើគ្នាចំពោះអ្នកទោសគ្រប់រូប ។

## ភ្នាក់ងារប្រចាំមន្ទីរឃុំឃាំង

៤៦. (១) រដ្ឋបាលគ្រប់គ្រងមន្ទីរឃុំឃាំងត្រូវផ្តល់បុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានមកពីការជ្រើសរើសយ៉ាងប្រុងប្រយ័ត្នបំផុត ព្រោះថាការគ្រប់គ្រងមន្ទីរឃុំឃាំងបានល្អត្រឹមត្រូវវាពឹងផ្អែកទៅលើសេចក្តីសុចរិត, មនុស្សធម៌សមត្ថភាពវិជ្ជាជីវៈហើយនឹងលក្ខណៈសម្បត្តិត្រូវនឹងការងាររបស់ពួកគេ

(២) រដ្ឋបាលគ្រប់គ្រងមន្ទីរឃុំឃាំង ត្រូវរំលឹកដាស់តឿនសតិអារម្មណ៍ទាំងបុគ្គលិក និងសាធារណៈជន ឲ្យចាំជាប់ជានិច្ចថា ការងារនេះគឺជាសេវាកម្ម "ការងារបំរើ" សង្គមមួយដ៏មានសារៈសំខាន់បំផុត ហើយក្នុងន័យនេះ រដ្ឋបាលគ្រប់គ្រង មន្ទីរឃុំឃាំង គួរតែប្រើប្រាស់គ្រប់មធ្យោបាយដ៏សមស្របទាំងអស់ដែលមាន ដើម្បីផ្សព្វផ្សាយដល់សាធារណៈជន ។

(៣) ដើម្បីឲ្យបានជោគជ័យតាមប្រាថ្នា បុគ្គលិកមន្ទីរឃុំឃាំងនឹងត្រូវតែបានចាត់តាំងជាមន្ត្រីពន្ធនាគារ ធ្វើការពេញម៉ោង និងមានឋានៈជាអ្នកបំរើក្រសួងស៊ីវិល ដែលមានការធានាក្នុងមុខតំណែង ដោយសំអាងទៅលើចរិយាល្អ, សុខភាពរាងកាយមាំមួន និងប្រកបដោយប្រសិទ្ធិភាពក្នុងការងារតែប៉ុណ្ណោះ។ ប្រាក់ខែត្រូវតែផ្តល់ឲ្យបានគ្រប់គ្រាន់ ដើម្បីទាក់ទាញ និងរក្សា បាននូវបុរសនិងស្រ្តី ដែលមានគុណសម្បត្តិ ផលប្រយោជន៍ដែលបានទទួលពីការងារនិងលក្ខខ័ណ្ឌនានានៃការបំរើការងារ ត្រូវតែ ឲ្យសមស្របទៅនឹងបុព្វហេតុពិតនៃការងារនេះ ។

៤៧. (១) បុគ្គលិកមន្ទីរឃុំឃាំងត្រូវមានចំណេះ និងប្រាជ្ញាស្មារតីគ្រប់គ្រាន់បរិបូណ

(២) មុននឹងចូលកាន់មុខតំណែងបុគ្គលិកមន្ទីរឃុំឃាំង ត្រូវតែបានទទួលការហ្វឹកហ្វឺនអំពីកិច្ចការទូទៅនិងកិច្ចការជាក់លាក់មួយចំនួន និងត្រូវតែប្រឡងជាប់ទាំងវិញ្ញាសារទ្រឹស្តីនិងការអនុវត្ត ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(៣) បន្ទាប់ពីចូលកាន់មុខតំណែង និង ក្នុងពេលបំពេញការងារ បុគ្គលិកត្រូវតែរក្សានិងបង្កើនសមត្ថភាពចំណេះវិជ្ជា និងវិជ្ជាជីវៈរបស់ខ្លួន តាមរយៈការចូលរួមក្នុងវគ្គហ្វឹកហ្វឺនបបណ្តើរធ្វើការបណ្តើរ ដែលរៀបចំឲ្យមាននៅចន្លោះពេលបំពេញ ការងារ ។

៤៨. សមាជិកនៃបុគ្គលិកទាំងអស់ ជានិច្ចជាកាលត្រូវដឹកនាំខ្លួនឲ្យមានចរិយាថ្លៃថ្នូរ និងបំពេញតាមភារកិច្ចរបស់ខ្លួន ដើម្បីធ្វើជាគំរូល្អដល់អ្នកទោសឲ្យទៅរកផ្លូវល្អ និងជាការធ្វើឲ្យអ្នកទោសមានការគោរពចំពោះបុគ្គលិកផង ។

៤៩. (១) យោងទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ក្នុងចំណោមបុគ្គលិកមន្ទីរឃុំឃាំងត្រូវមានអ្នកទេសគ្រប់គ្រាន់មួយចំនួន ដូចជាគ្រូពេទ្យវិកលចរិត "គ្រូពេទ្យព្យាបាលមនុស្សឆ្កួត" អ្នកចិត្តវិជ្ជា, បុគ្គលិកសង្គមកិច្ច, គ្រូបង្រៀន និងគ្រូបង្ហាត់ ខាងវិជ្ជាជីវៈជាដើម ។

(២) សេវាកម្មរបស់បុគ្គលិកសង្គមកិច្ច, គ្រូបង្រៀន និងគ្រូបង្ហាត់ខាងវិជ្ជាជីវៈ ត្រូវធានាឲ្យមានលក្ខណៈអចិន្ត្រៃយ៍ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏គ្មានការផាត់ចេញអ្នកធ្វើការដោយស្ម័គ្រចិត្តឬអ្នកធ្វើតែកន្លះថ្ងៃ "កន្លះពេល" ឡើយ។

៥០. (១) នាយកមន្ទីរឃុំឃាំងត្រូវតែជាមនុស្សដែលមានគុណសម្បត្តិគ្រប់គ្រាន់ត្រូវនឹងការងាររបស់គាត់ ពោលគឺត្រូវ មានអត្តចរិតថ្លៃថ្នូរ, មានសមត្ថភាពក្នុងការគ្រប់គ្រង, មានបទពិសោធន៍និងការហ្វឹកហ្វឺនគ្រប់គ្រាន់ ។

(២) គាត់ "នាយកមន្ទីរឃុំឃាំង" ត្រូវបូជាពេលវេលារបស់គាត់ទាំងស្រុងជូនចំពោះកាតព្វកិច្ចផ្លូវការរបស់គាត់ ហើយមិនត្រូវតែងតាំងជាបុគ្គលិកធ្វើការកន្លះថ្ងៃឡើយ ។

(៣) គាត់ត្រូវស្នាក់នៅក្នុងបរិវេណ នៃមន្ទីរឃុំឃាំង ឬក៏នៅម្តុំជិតៗមន្ទីរឃុំឃាំងនោះ ។

(៤) កាលណាមានមន្ទីរឃុំឃាំងពីរ ឬច្រើនជាងពីរស្ថិតនៅក្រោមអំណាចគ្រប់គ្រងនាយកតែម្នាក់ នាយករូបនោះត្រូវទៅពិនិត្យមន្ទីរឃុំឃាំងទាំងនោះឲ្យបានញឹកញាប់។ ប៉ុន្តែ ត្រូវមានមន្ត្រីទទួលខុសត្រូវម្នាក់នៅប្រចាំការតាមមន្ទីរឃុំឃាំង និមួយៗ នោះ។

៥១. (១) ទាំងនាយក ទាំងនាយករង និងបុគ្គលិកភាគច្រើននៃមន្ទីរឃុំឃាំង ត្រូវតែចេះនិយាយភាសារបស់អ្នកទោស ភាគច្រើន ឬក៏ភាសាណាមួយដែលអ្នកទោសភាគច្រើនអាចស្តាប់យល់ ។

(២) នៅពេលចាំបាច់ ត្រូវប្រើប្រាស់អ្នកបកប្រែភាសា ។


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៥២. (១) នៅមន្ទីរឃុំឃាំងណាមានបរិវេណទូលាយគ្រប់គ្រាន់ ដែលត្រូវការសេវាកម្មពេទ្យពេញម៉ោងម្នាក់ ឬច្រើននាក់នោះ យ៉ាងហោចណាស់ក៏ត្រូវឲ្យគ្រូពេទ្យម្នាក់ស្នាក់នៅក្នុងបរិវេណនៃមន្ទីរ ឃុំឃាំង ឬនៅក្តុំជិតៗមន្ទីរឃុំឃាំងនោះ ។

(២) មន្ទីរឃុំឃាំងដ៏ទៃៗខ្លះទៀត គ្រូពេទ្យត្រូវចុះពិនិត្យសុខភាពរៀងរាល់ថ្ងៃហើយត្រូវនៅក្បែរៗមន្ទីរឃុំឃាំង នោះ ដើម្បីអាចទៅពិនិត្យអ្នកជម្ងឺក្នុងមន្ទីរឃុំឃាំងបានភ្លាមៗ នៅពេលណាមានការបន្ទាន់

៥៣. (១) ក្នុងមន្ទីរឃុំឃាំងណាដែលដាក់អ្នកទោសប្រុសផងស្រីផងនោះ ផ្នែកខាងអ្នកទោសស្រីត្រូវតែស្ថិតនៅក្រោមអាជ្ញាធរទទួលខុសត្រូវដាច់មុខដោយមន្ត្រីមន្ទីរឃុំឃាំងស្ត្រី ហើយជាអ្នកកាន់កូនសោរទាំងអស់ ដែលសំរាប់ប្រើនៅផ្នែកខាងស្ត្រី។

(២) មិនត្រូវឲ្យមានបុគ្គលិកបុរសចូលទៅក្នុងកន្លែងដាក់អ្នកទោសលើយឡើយ ប្រសិនបើមិនមានបុគ្គលិកស្ត្រីជូនទៅជាមួយទេនោះ ។

(៣) អ្នកទោសស្រីៗត្រូវតែស្ថិតនៅក្រោមការថែរក្សា និងត្រួតពិនិត្យដោយបុគ្គលិកស្រីប៉ុណ្ណោះ ទោះជា យ៉ាងណាក៏ដោយ ប្រការនេះមិនមែនបានសេចក្តីថា ត្រូវបដិសេធចំពោះបុគ្គលិកប្រុសទាំងអស់ មិនឲ្យចូលទៅបំពេញភារកិច្ចរបស់ គេនៅក្នុងមន្ទីរឃុំឃាំង ឬកន្លែងដាក់អ្នកទោសស្រីៗឡើយ ជាពិសេស គ្រូពេទ្យនិងគ្រូបង្រៀន ។

៥៤. (១) ក្នុងការទំនាក់ទំនងជាមួយអ្នកទោសមន្ត្រីមន្ទីរឃុំឃាំងមិនត្រូវប្រើកម្លាំងឡើយ លើកលែងតែក្នុងករណីការពារខ្លួន, ករណីអ្នកទោសរត់ចេញក្រៅ, អ្នកទោសតដៃ ឬប្រឆាំងដោយប្រយោល ឬដោយផ្ទាល់ទៅនឹងបញ្ជាស្របតាមច្បាប់ ឬស្របតាមបទបញ្ជានានារបស់មន្ទីរឃុំឃាំង ។ មន្ត្រីមន្ទីរឃុំឃាំងណាដែលប្រើកម្លាំងដើម្បីដោះទ័លនោះ ក៏មិនត្រូវប្រើឲ្យហួសពីកំរិតដ៏ចាំបាច់ឡើយ ហើយត្រូវរាយការណ៍ភ្លាមៗទៅនាយកមន្ទីរឃុំឃាំងអំពីឧប្បត្តិហេតុនោះ ។

(២) មន្ត្រីពន្ធនាគារត្រូវតែបានទទួលការហ្វឹកហាត់ខាងកាយសម្បទាគ្រប់គ្រាន់ ដើម្បីឲ្យគេមានលទ្ធភាពអាច ទប់ទល់បានជាមួយនឹងអ្នកទោសកាចៗ “ កំរោល “។

(៣) លើកលែងតែក្នុងកាលៈទេសៈពិសេសចេញ បុគ្គលិកដែលត្រូវបំពេញភារកិច្ចដោយផ្ទាល់ជាមួយអ្នកទោស មិនត្រូវឲ្យមានអាវុធឡើយ។ លើសពីនេះទៀត ទោះក្នុងករណី


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ណាក៏ដោយ មិនត្រូវឲ្យបុគ្គលិកកាន់អាវុធឡើយ ប្រសិន បើមិនទាន់បានទទួលការហ្វឹកហាត់អំពីរបៀបប្រើអាវុធទេនោះ។

## ការត្រួតពិនិត្យ

៥៥.គ្រប់មន្ទីរឃុំឃាំងទាំងអស់ ត្រូវតែឲ្យមានការត្រួតពិនិត្យយ៉ាងទៀងទាត់។ អ្នកមានភារកិច្ចក្នុងការត្រួតពិនិត្យនេះ គឺអធិការដែលក្រសួងមានសមត្ថកិច្ចបានតែងតាំងយ៉ាងត្រឹមត្រូវតាមក្បួនច្បាប់។ ពួកអធិការគុកគឺជាមនុស្សដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងមានការពិសោធន៍គ្រប់គ្រាន់ក្នុងក្រសួងគុក។ ភារកិច្ចរបស់អធិការគុកគឺមើលការខុសត្រូវអំពីរបបគ្រប់គ្រងអ្នកទោសក្នុងគុក។ គេត្រូវការត្រួតពិនិត្យឲ្យដិតដល់ថាតើរបបគ្រប់គ្រងក្នុងគុកនិមួយៗ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ និងបទ វិន័យឬទេ, តើរបបគ្រប់គ្រងសព្វថ្ងៃឆ្លើយតបទៅនឹងគោលដៅរបស់មន្ទីរឃុំឃាំងឬទេ? គោលដៅសំខាន់របស់មន្ទីរឃុំឃាំង គឺ ពុំមែនសំរាប់តែដាក់ទណ្ឌកម្មឲ្យមនុស្សរៀងចាលតែប៉ុណ្ណោះទេ គឺបង្ហាត់បង្រៀន និងហ្វឹកហ្វឺនពួកអ្នកទោសអោយកសាងខ្លួនទៅជាសមាជិកដ៏ល្អមួយនៅក្នុងសង្គមមនុស្សធម៌ (សង្គមដែលនៅក្រៅមន្ទីរឃុំឃាំង)។


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

# ជំពូកទី ២

# បទវិន័យសំរាប់ប្រើប្រាស់តាមប្រភេទអ្នកទោស

## ក- អ្នកទោសដែលតុលាការវិនិច្ឆ័យទោស

## (គោលការណ៍ណែនាំ)

៥៦. សេចក្តីណែនាំជាគោលៗខាងក្រោមនេះ សំរាប់បងាញនូវស្មារតីដែលយល់ថា តើមន្ទីរឃុំឃាំងគួរឲ្យមានការគ្រប់គ្រងតាមរបៀបណា ហើយនិងគោលដៅដែលត្រូវសំដៅយកដូចមានចែងនៅក្នុងវគ្គទី១ នៃសេចក្តីប្រកាសរបស់បុព្វកថា នៃអត្ថបទនេះ ។

៥៧. ការដាក់គុក ហើយនឹងវិធានការដ៏ទៃទៀត ដែលបណ្តាលឲ្យពិរុទ្ធិជនដាក់ការទាក់ទងជាមួយអ្នកដ៏ទៃ ជាការមួយ ដែលធ្វើឲ្យមនុស្សកើតការឈឺចាប់ ព្រោះបុគ្គលរូបនេះពុំមានសិទ្ធិក្នុងការសំរេច ចិត្តដោយខ្លួនឯង ដោយសារត្រូវគេដកហូតសេរីភាពចេញពីខ្លួន។ ដូច្នេះក្រៅអំពីការឃុំឃាំងដោយមានមូលហេតុត្រឹមត្រូវម្តងម្កាល ហើយនឹងការរក្សាវិន័យក្នុងគុករបបគ្រប់គ្រងនៅក្នុងមន្ទីរឃុំឃាំង មិនត្រូវបង្កើនសេចក្តីទុក្ខសោកឈឺចាប់ទៅលើពួកអ្នកទោសដែលកំពុងតែមានការឈឺចាប់ (ដោយសារ គ្មានសេរីភាព) នោះទៀតឡើយ ។

៥៨. គោលដៅ និងមូលហេតុនៃការកាត់ទោសដាក់គុក ឬតាមមធ្យោបាយទៀត ដើម្បីមិនឲ្យសាម៉ីខ្លួនមានសេរីភាព គឺវិសេសបំផុត ដើម្បីការពារសង្គមមនុស្សកុំឲ្យមានអំពើឧក្រិដ្ឋ។ គោលដៅនេះនឹងសំរេចទៅបាន លុះត្រាតែមានការអប់រំឲ្យបាន ខ្ពង់ខ្ពស់បំផុតដល់អ្នកទោសដែលកំពុងនៅក្នុងគុក ហើយពេលចេញពីគុកវិញ បុគ្គលនេះមិនត្រឹមតែក្លាយជាមនុស្ស ដែលមានបំណងចង់គោរពច្បាប់តែប៉ុណ្ណោះទេ តែក្លាយទៅជាមនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រតិបត្តិតាមច្បាប់ និងប្រកបរបរចិញ្ចឹម ជីវិតដោយខ្លួនឯងទៀតផង ។

៥៩ ក្នុងទិសដៅនេះ មន្ទីរត្រូវប្រើគ្រប់មធ្យោបាយដែលសមរម្យ និងដែលអាចរកបានទាំងមធ្យោបាយអប់រំ មធ្យោបាយដោះស្រាយបញ្ហា មធ្យោបាយផ្នែកសីលធម៌ និងខាងគំនិតស្មារតី ហើយនិងមធ្យោបាយដ៏ទៃទៀត ព្រមទាំងជំនួយគ្រប់បែបយ៉ាង ដែលអាចរកបាន ហើយត្រូវព្យាយាមប្រើវាតាមលំនាំនៃ សេចក្តីត្រូវការ ក្នុងការគ្រប់គ្រងអ្នកទោសមួយរូបៗ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៦០. (១) របបគ្រប់គ្រងនៃ មន្ទីរឃុំឃាំង ត្រូវធ្វើយ៉ាងណាកុំឲ្យការរស់នៅក្នុងគុក ខុសគ្នាឆ្ងាយពេកអំពីជីវិត ដែល ប្រកបដោយសេរីភាពនៅក្រៅគុក គឺដើម្បីជួយសំរាលបន្ទុកដល់អ្នកទោស ហើយនិងបង្កើនការគោរពដល់សេចក្តីថ្លៃថ្នូររបស់គេ ក្នុងនាមជាមនុស្ស ។

(២) មុនពេលចប់អាណត្តិរបស់អ្នកទោសម្នាក់ៗ មន្ទីរឃុំឃាំងត្រូវចាត់ឲ្យមានវិធានការអប់រំតំរង់ទិស ដើម្បីធ្វើយ៉ាងណា ឲ្យអ្នកទោសមានការពិសោធន៍ក្នុងជីវភាពធម្មតា (គឺជីវភាពរស់នៅធម្មតាខាងក្រៅគុក) ជាលំដាប់លំដោយទំរាំដល់ ថ្ងៃចេញ។ សកម្មភាពអប់រំបែបនេះអាចធ្វើនៅក្នុងមន្ទីរ ឃុំឃាំងដ៏ទៃទៀតក៏បានប្រសិនបើអាចធ្វើទៅកើតគួរសាកល្បងឲ្យអ្នកទោសទៅរៀនរស់ក្រៅឃុំ

(ឬក្រៅគុក) ដោយចាត់ឲ្យមានការតាមដានពិនិត្យពិច័យយ៉ាងជិតដល់។ ការពិនិត្យពិច័យនេះមិនត្រូវ ស្ថិត នៅក្រោមអាជ្ញាប៉ូលីសទេ ប៉ុន្តែគួរអោយមានសហប្រតិបត្តិការពីសំណាក់ក្រុមជំនួយសង្គមដ៏មានប្រសិទ្ធិភាព ។

៦១. ក្នុងការគ្រប់គ្រង មិនត្រូវធ្វើងយ៉ាងណាឲ្យអ្នកទោសយល់ថាពួកគេជាមនុស្សក្រៅសង្គមទេ ផ្ទុយទៅវិញត្រូវណែនាំ ឲ្យគេយល់ថា ថ្វីត្បិតតែគេរស់នៅក្នុងគុក ពួកគេនៅតែមានលក្ខណៈជាអ្នករួមរស់ក្នុងសង្គមដែរ។ ត្រូវអនុញ្ញាតិឲ្យភ្នាក់ងារតំណាង សហគមន៍មានឱកាសរួមសហប្រតិបត្តិការជាមួយបុគ្គលិកធ្វើការប្រចាំមន្ទីរដែលទទួលភារៈផ្តល់ឲ្យអ្នកទោសនូវលទ្ធភាពផ្នែក សង្គមសារឡើងវិញ។ដោយមានទំនាក់ទំនងជាមួយមន្ទីរនានាផង គួរតែមានអ្នកធ្វើការខាងវិស័យសង្គមកិច្ច ដែលទទួលភារៈថែរក្សា និងបង្កើនចំណងមេត្រីភាពរវាងពួកអ្នកទោស និងក្រុមគ្រួសាររបស់គេ និងជាមួយទីភ្នាក់ងារសង្គមកិច្ច។ ដើម្បីបង្កើនភាពស្របគ្នារវាងច្បាប់គ្រប់គ្រង ហើយនឹងការកាត់ទោសដាក់ទណ្ឌកម្ម ត្រូវឲ្យមានផែនការសំរាប់ការពារសិទ្ធិដែលទាក់ទងដល់ផល ប្រយោជន៍ប្រជាជន សិទ្ធិក្នុងការទទួលប្រាក់ជំនួយសំរាប់មនុស្សចាស់ជរាឬពិការហើយនឹងជំនួយផ្នែកសង្គមកិច្ចទៀតៗ របស់ ពួកអ្នកទោស។

៦២. កិច្ចការរបស់គ្រូពេទ្យប្រចាំមន្ទីរឃុំឃាំង គឺត្រូវខំស្វះស្វែងពិនិត្យរកឲ្យឃើញ ហើយនឹងព្យាបាលជម្ងឺនានា ដែល មានជាអាទិ៍ដូចជា ជម្ងឺខាងរាងកាយ ជម្ងឺខួរក្បាល ឬភាពមិនគ្រប់លក្ខណៈក្នុងប្រការណាមួយ ដែលជាឧបសគ្គរាំងមិនឲ្យអ្នកទោសកសាងខ្លួនឲ្យបានល្អឡើងវិញ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

។ ការព្យាបាលចាំបាច់ទាំងអស់ខាងផ្នែកថ្នាំសង្កូវ ផ្នែកវះកាត់ ហើយនឹងផ្នែកវិកលចរិត ត្រូវសំដៅយកតាមគោលដៅដូចចែងខាងលើ ។

៦៣. (១) ដើម្បីឲ្យបានសំរេចតាមគោលការណ៍ខាងលើនេះ ត្រូវអនុវត្តន៍តាមវិធីពិនិត្យព្យាបាលអ្នកទោសម្នាក់ម្តងៗ ហើយដើម្បីឲ្យងាយក្នុងការអនុវត្តតាមវិធីនេះ ត្រូវចែកពួកអ្នកទោសជាក្រុមៗ ទៅតាមប្រភេទ និងលក្ខណៈរបស់គេ ដោយ អនុវត្តន៍តាមរបៀបដែលអាចផ្លាស់ប្តូរបានតាមកាលៈទេសៈ។ ជាការកាន់តែប្រសើ ប្រសិនបើគេអាចដាក់ពួកអ្នកទោសប្រភេទ ដូចគ្នានៅក្នុងមន្ទីរតែមួយ ហើយប្រភេទផ្សេងៗទៀតនៅក្នុងមន្ទីរផ្សេងៗដោយឡែកពីគ្នា ដើម្បីសម្រួលក្នុងកិច្ចព្យាបាលក្រុមនីមួយៗ ។

(២) មន្ទីរឃុំឃាំងទាំងនេះពុំចាំបាច់ផ្តល់សន្តិសុខក្នុងកំរិតដូចៗគ្នានៅគ្រប់ក្រុមទាំងអស់ទេ។ ការផ្តល់សន្តិសុខ ក្នុងកំរិតតិច ឬច្រើនត្រូវអាស្រ័យទៅលើសេចក្តីត្រូវការរបស់ក្រុមនិមួយៗ។ មន្ទីរឃុំឃាំងដែលមានសុទ្ធតែពួកអ្នកទោស ដែល ប្រកបដោយចរិតលក្ខណៈល្អ ចេះស្រឡាញ់ និងគោរពវិន័យរបស់មន្ទីរ ហើយដែលគ្មានសញ្ញាបង្ហាញថាចង់រត់ចេញពីគុក គួរចំហរ ទ្វារអនុញ្ញាតិឲ្យពួកគេចេញចូលតាមប្រាថ្នា (ប៉ុន្តែត្រូវយោលទៅតាមវិន័យផងដែរ)។ មន្ទីរឃុំឃាំងចំហរបែបនេះ អាចបង្កើត លក្ខណៈ ដ៏ល្អប្រពៃបំផុត ក្នុងការអប់រំកសាងខ្លួននៃពួកអ្នកទោសទាំងឡាយណាដែលគេទុកចិត្ត ។

(៣) នៅក្នុងមន្ទីរឃុំឃាំងធម្មតា (គឺគុកដែលចាក់សោរទ្វារ) ពុំគួរដាក់អ្នកទោសច្រើនហួសពេក ដែលជាឧបសគ្គរាំងមិនអោយការត្រួតពិនិត្យនិងការអប់រំណែនាំអ្នកទោសតាមវិធីម្នាក់ម្តង អាចប្រព្រឹត្តិទៅកើត។ នៅប្រទេសខ្លះ គេហាម មិនឲ្យមានអ្នកទោសច្រើនជាងប្រាំរយនាក់ទេ នៅក្នុងគុកនិមួយៗរីឯមន្ទីរឃុំឃាំងចំហរទ្វារ (ឬគួរហៅថាមន្ទីរកសាងខ្លួន) គួររក្សាចំនួនអ្នកទោសឲ្យនៅតិចបំផុត (ដើម្បីអោយស្រួលត្រួតពិនិត្យ) ។

(៤) ម្យ៉ាងវិញទៀត មិនត្រូវទុកអ្នកទោសឲ្យនៅចំនួនតិចហួសហេតុពេកទេ ព្រោះក្រសួងមិនអាចឧបត្ថមឲ្យបានសមរម្យដូចនៅក្នុងគុកធម្មតាឡើយ ។

៦៤. កាតព្វកិច្ចរបស់សង្គម មិនមែនចប់នៅត្រឹមការដោះលែងអ្នកទោសតែប៉ុណ្ណឹងទេ។ យ៉ាងណាមិញ ត្រូវតែមានទី ភ្នាក់ងារឯកជនឬទីភ្នាក់ងាររដ្ឋភិបាល ដែលមានសមត្ថភាពអាចឧបត្ថម្ភដល់ពួក ដែលទើបនឹងរួចពីគុកនូវជំនួយដ៏ស័ក្តិសិទ្ធិគ្រប់ប្រការក្នុងទិសដៅបន្ថយ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ការរើសអើងប្រឆាំងនឹងពួកគេ ហើយនឹងក្នុងទិសដៅផ្តល់លទ្ធភាពសារជាថ្មីឡើងវិញ ក្នុងការរៀនរស់នៅ ក្នុងសង្គម ។

## ការគ្រប់គ្រង

៦៥. ការគ្រប់គ្រងអ្នកទោសនៅក្នុងមន្ទីរឃុំឃាំង ឬក្នុងគុក ត្រូវសំដៅយកការហ៊ឹកហ្វឺន និងអប់រំណែនាំជានិច្ចជាកាល ដើម្បីឲ្យចេះស្រឡាញ់និងគោរពច្បាប់ ឲ្យចេះប្រកបរបរចិញ្ចឹមជីវិតខ្លួនដោយខ្លួនឯង ក្រោយពេលដែលសាម៉ីខ្លួនរួចពីគុកវិញ។ ក្នុងទិសដៅនេះ ត្រូវជំរុញអ្នកទោសឲ្យចេះគោរពសេចក្តីថ្លៃថ្នូររបស់ខ្លួនគេ ព្រមទាំងឲ្យចេះស្គាល់ករណីយកិច្ច និងការទទួលខុសត្រូវផ្ទាល់ខ្លួន ។

៦៦. (១) ដើម្បីសំរេចតាមទិសដៅនេះ ត្រូវប្រើគ្រប់មធ្យោបាយណាដែលសមរម្យ ដោយមានជាអាទិ៍គឺការទ្រទ្រង់ សាសនា អាស្រ័យទៅលើលទ្ធភាពនៅក្នុងប្រទេសនិមួយៗ ការអប់រំ ការហ្វឹកហ្វឺន និងការណែនាំខាងវិជ្ជាជីវៈ បញ្ហាការងារសង្គម កិច្ចការពន្យល់ណែនាំក្នុងរឿងរកការងារធ្វើ ការព្រងឹកកាយវប្បកម្ម និងពង្រឹងអត្តចរិតផ្នែកសីលធមិ ឲ្យបានសម្របទៅតាមសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់អ្នកទោសម្នាក់ៗ ដោយពិនិត្យគិតគូរឲ្យបានដិតដល់ផងដែរទៅលើប្រវត្តិរបស់គេក្នុងវិស័យឧក្រិដ្ឋកម្ម និងសង្គមមនុស្ស សមត្ថភាពខាងកម្លាំងកាយ និងកម្លាំងចិត្តសម្បទា អធ្យាស្រ័យប្រចាំកាយរបស់គេ កំឡុងពេលដែលគេត្រូវនៅ ក្នុងគុក ហើយនឹងសេចក្តីសង្ឃឹមរបស់គេក្រោយពេលដែលគេរួចពីគុក។

(២) សំរាប់អ្នកទោសម្នាក់ ដែលត្រូវនៅជាប់ក្នុងគុកយ៉ាងយូរបង្គួរ ចាងហ្វាងគុកត្រូវតែបានទទួលសេចក្តីរាយការណ៍ឲ្យបានសព្វគ្រប់អំពីប្រការនានា ដែលនឹងរៀបរាប់នៅវគ្គខាងក្រោមនេះ។ សេចក្តីរាយការណ៍នេះ ត្រូវប្រគល់ឲ្យចាងហ្វាង គុកក្រោយពីពេលដែលគេបញ្ជូនអ្នកទោសមកដល់គុកភ្លាម។ នៅក្នុងសេចក្តីរាយការណ៍ ត្រូវរាប់បញ្ចូលកុំខានន្ធូវរបាយការណ៍ របស់គ្រូពេទ្យដែលមានគុណសម្បត្តិខាងវេជ្ជវិទ្យាផ្នែកវិកលចរិត ព្រមទាំងអាចពិនិត្យលក្ខណៈខាងផ្លូវកាយ និងផ្លូវចិត្តរបស់ពួក អ្នក ទោសផង ។

(៣) របាយការណ៍ និងឯកសារទាក់ទិនផ្សេងៗទៀត ត្រូវរក្សានៅក្នុងសំណុំឯកសារម្នាក់ៗដោយឡែកពីគ្នា ។ សំណុំឯកសារទាំងនេះ ត្រូវតែមានពត៌មានប្រចាំថ្ងៃស្តីអំពីហេតុការណ៍នានា


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ដែលទាក់ទងដល់អ្នកទោសម្នាក់ៗ ហើយរៀបតាម លំដាប់ត្រឹមត្រូវ ដើម្បីជាការងាយស្រួល ដល់បុគ្គលិកធ្វើការ ជាពិសេសនៅពេលណាដែលគេត្រូវការពិនិត្យសំណុំរឿងរបស់អ្នកទោស ។

## ការចែកអ្នកទោសតាមប្រភេទលក្ខណៈ និង ការគ្រប់គ្រងអ្នកទោសតាមវិធីម្នាក់ម្តង

៦៧. គោលបំណងនៃការចែកប្រភេទអ្នកទោសគឺៈ

(១) ដើម្បីអោយនៅដាច់ដោយឡែកអំពីពួកដែលអាចបង្កើតឲ្យមានឥទ្ធិពលអាក្រក់ទៅលើអ្នកទោសដទៃទៀត ដោយ ផ្អែកទៅលើឯកសារឧក្រិដ្ឋ ឬចរិតបូកពារមិនល្អរបស់ពួកអស់ទាំងនោះ ។

(២) ចែកពួកអ្នកទោសជាក្រុមៗ ដើម្បីឲ្យងាយស្រួលដល់ការគ្រប់គ្រង និងត្រួតពិនិត្យក្នុងការកសាងខ្លួនពួកអ្នកទោស ឲ្យចេះរស់ក្នុងសង្គម ។

៦៨. បើអាចធ្វើទៅកើត គួរចែកមន្ទីរឃុំឃាំងឲ្យដាច់ដោយឡែកពីគ្នា យោលទៅតាមប្រភេទអ្នកទោសឬបើមន្ទីរ ឃុំឃាំងមានតែមួយគត់ គួរខាន់ជាផ្នែកផ្សេងៗគ្នា សំរាប់អ្នកទោសប្រភេទខុសៗគ្នា។ធ្វើយ៉ាងនេះគឺដើម្បីឲ្យងាយស្រួលក្នុងការ គ្រប់គ្រងគ្រប់វិស័យ ។

៦៩. ក្រោយពេលដែលអ្នកទោសចូលមកដល់មន្ទីរឃុំឃាំងភ្លាម ហើយក្រោយពីបានពិនិត្យសិក្សាឲ្យដឹងច្បាស់អំពីចរិយា សម្បត្តិរបស់អ្នកទោសណាដែលត្រូវជាប់គុកយូរគួរសម ត្រូវរៀបចំឲ្យមានកម្មវិធីសំរាប់គ្រប់គ្រងអប់រំមួយឲ្យស្របទៅតាមលក្ខណៈនៃសេចក្តីត្រូវការផ្ទាល់ខ្លួន សមត្ថភាពខាងផ្លូវកាយ និងផ្លូវចិត្ត ហើយនឹងអារម្មណ៍របស់អ្នកទោសម្នាក់ៗ ។

## សិទ្ធិពិសេសតាមលក្ខណៈសម្បត្តិ

៧០. ការឲ្យសិទ្ធិពិសេស ហើយនឹងពិធីគ្រប់គ្រងខុសៗគ្នាទៅតាមលកក្ខណៈនិងប្រភេទអ្នកទោស គួរតែបង្កើតឲ្យមាននៅគ្រប់មន្ទីរឃុំឃាំង ដើម្បីអប់រំកសាងអ្នកទោសឲ្យមានគំនិតមាយាទល្អ ឲ្យរីកចំរើននូវទឹកចិត្តចេះទទួលខុសត្រូវឲ្យចេះរក្សាការពារ ផលប្រយោជន៍ ហើយនឹងឲ្យមានសហប្រតិបត្តិការនៅក្នុងការគ្រប់គ្រងនេះ ។

## ការងារ

៧១. (១) ការងារនៅក្នុងគុកមិនត្រូវឲ្យមានលក្ខណៈដែលធ្វើឲ្យមានមនុស្សរងទុក្ខវេទនាទេ ។


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(២) អ្នកទោសគ្រប់រូបត្រូវធ្វើការងារ ប្រសិនបើគ្រូពេទ្យសំរេចថាពួកគេមានសុខភាពបរិបូណ៌ទាំងខាងផ្លូវកាយ និងផ្លូវចិត្ត ។

(៣) ត្រូវមានកិច្ចការដែលមានប្រយោជន៍ចំពោះសង្គមមនុស្ស សំរាប់ពួកអ្នកទោស ដើម្បីអោយពួកគេមាន ការងារធ្វើយ៉ាងសកម្មរាល់ថ្ងៃធ្វើការ ។

(៤) ត្រូវផ្តល់កិច្ចការប្រភេទណាដែលអាចជួយរក្សា ឬបង្កើនសមត្ថភាពពួកអ្នកទោសអោយបានច្រើនបំផុត ក្នុងការប្រកបរបរចិញ្ចឹមជីវិតដោយសុចរិតក្រោយពេលចេញពីគុកទៅ ។

(៥) ការហ្វឹកហ្វឺនវិជ្ជាជីវៈក្នុងផ្នែកពាណិជ្ជកម្ម ត្រូវតែឧបត្ថម្ភឲ្យបានច្រើន ដើម្បីឲ្យអ្នកទោសចេះរកចំណេញ ក្នុងមុខរបរ ជាពិសេសសំរាប់ពួកទោសក្មេងៗ ។

(៦) ត្រូវអនុញ្ញាតិអោយអ្នកទោសជ្រើសរើសប្រភេទការងារដែលគេចង់ធ្វើ។ ប៉ុន្តែការជ្រើសរើសនេះ ត្រូវ ស្ថិតនៅក្នុងក្របខ័ណ្ឌនៃបទវិន័យ ស្របទៅតាមផែនការរបស់ក្រសួងអភិបាលនៃមន្ទីរឃុំឃាំង ព្រមទាំងមិនអោយហួសពីព្រំដែន ដែលគេកំរិតឡើយ ។

៧២. (១) ការរៀបចំការងារ និងវិធីធ្វើការនៅក្នុងគុក ត្រូវឲ្យមានលកក្ខណៈស្រដៀងគ្នាទៅ នឹងប្រភេទនិងបែបបទនៃការងារនៅក្រៅគុក ដើម្បីជួយរៀបចំខ្លួនពួកអ្នកទោសឲ្យបានជ្រួតជ្រាបយ៉ាងខ្លាំងបំផុត ទៅក្នុងស្ថានភាពនៃរបររកស៊ីធម្មតា ។

(២) ក្នុងការការពារផលប្រយោជន៍អ្នកទោស ហើយនឹងការហ្វឹកហ្វឺនរបរអាជីវកម្មត្រូវ ធ្វើយ៉ាងណាកុំបណ្តោយឲ្យពួកអ្នកទោសយល់ច្រឡំ ហើយមានចិត្តប៉ុនប៉ងចង់គេងចំណេញជាប្រាក់កាស អំពីកម្មវិធីអប់រំក្នុងមន្ទីរឃុំឃាំង ។

៧៣. (១) ការហ្វឹកហ្វឺនក្នុងវិស័យឧស្សាហកម្មនិងកសិកម្ម គួរតែស្ថិតនៅក្រោមការត្រួតត្រា ដោយផ្ទាល់របស់អភិបាលមន្ទីរឃុំឃាំង ពុំគួរអោយនៅក្រោមការដឹកនាំនៃពួកឯកជនដែលជាអ្នកម៉ៅការពីរដ្ឋទេ។

(២) ទីណាដែលអ្នកទោសទៅធ្វើការ ទោះមិននៅក្រោមការគ្រប់គ្រងរបស់ក្រុមអភិបាលក្តីក៏ត្រូវតែឲ្យមាន បុគ្គលិកមន្ទីរតាមមើលការខុសត្រូវជានិច្ចជាកាលដែរ។ ប៉ុន្តែប្រសិនបើការងាររបស់ក្រសួងដ៏ទៃៗទៀតរបស់រដ្ឋាភិបាល ព្រប្រាក់ខែ (ដែលត្រូវមានចំនួនពេញលេញដូចប្រាក់ខែធម្មតា) ។


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៧៤. (១) ច្បាប់ដែលចែងឲ្យមានវិធីសំរាប់ការពារដល់សន្តិសុខនិងសុខភាពរបស់អ្នកធ្វើការ ត្រូវយកទៅអនុវត្តន៍ ឲ្យបានដូចគ្នានៅក្នុងមន្ទីរឃុំឃាំង ។

(២) ច្បាប់ត្រូវចែងឲ្យមានការសងជម្ងឺចិត្តដល់ពួកអ្នកទោស ក្នុងករណីដែលមានគ្រោះថ្នាក់ក្នុងការងារ ដោយ រាប់បញ្ចូលទាំងជម្ងឺជំកាត់នានា ដែលបណ្តាលមកពីលកក្ខណៈនៃការងារផងដែរ ពោលគឺអ្នកទោសត្រូវបានទទួលប្រាក់សងជម្ងឺចិត្ត ព្រមទាំងលក្ខខ័ណ្ឌផ្សេងៗទៀតដូចគ្នានឹងប្រជាពលរដ្ឋទៀតៗដែរ ។

៧៥. (១) ចំនួនពេលម៉ោងដែលច្រើនបំផុតប្រចាំថ្ងៃ ឬប្រចាំអាទិត្យសំរាប់ឲ្យពួកអ្នកទោសធ្វើការត្រូវកំណត់ តាមច្បាប់ ឬតាមបទបញ្ជានៃអភិបាលមន្ទីរ ដោយអនុលោមទៅតាមច្បាប់ប្រចាំតំបន់ ឬទំលាប់របស់អ្នកធ្វើការជាទូទៅ ។

(២) ក្នុងការកំរិតពេលម៉ោងសំរាប់ធ្វើការ ត្រូវរក្សាទុកពេលសំរាកយ៉ាងតិចណាស់មួយ ថ្ងៃក្នុងមួយអាទិត្យ។ លើសពីនេះទៅទៀត ត្រូវលៃពេលឲ្យបានគ្រប់គ្រាន់សំរាប់ឲ្យពួកអ្នកទោសបានសិក្សារៀនសូត្រ ហើយនឹងចូលរួមក្នុងសកម្មភាពផ្សេងៗទៀត ដែលមន្ទីរបានតម្រូវឲ្យ ដើម្បីឲ្យពួកគេអាច កសាងខ្លួនបាន ។

៧៦. (១) ត្រូវតែមានប្រព័ន្ធដើម្បីឲ្យប្រាក់រង្វាន់ ប្រាក់សងជម្ងឺចិត្ត ហើយនឹងប្រាក់កំរៃផ្សេងៗ ចំពោះការងាររបស់ ពួកអ្នកទោស ។

(២) នៅក្នុងរបៀបចាត់ចែងប្រាក់កំរៃនេះ ត្រូវអនុញ្ញាតិឲ្យអ្នកទោសមានសិទ្ធិចាយវាយភាគខ្លះនៃប្រាក់ដែល គេរកបាន ដើម្បីទិញរបស់របរខ្លះៗ ក្រសួងបានអនុញ្ញាតិសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនឬធ្វើជាប្រាក់ខ្លះទៅឲ្យបងប្អូនគ្រួសារគេ ។

(៣) របៀបចាត់ចែងប្រាក់កាសរបស់អ្នកទោស គឺត្រូវរៀបចំឲ្យមានការសន្សំ ដើម្បីទុកសំរាប់ប្រគល់ឲ្យអ្នកទោស នៅថ្ងៃចេញពីគុក ។

## ការអប់រំនិងការកំសាន្ត

៧៧. (១) ត្រូវចាត់ឲ្យមានការសិក្សាអប់រំនៅក្នុងគុក ដើម្បីជាប្រយោជន៍ដល់ពួកអ្នកទោស ។ ការសិក្សាក្នុងវិស័យ សាសនា ក៏គួររៀបចំឲ្យមានដែរ ប្រសិនបើមានលទ្ធភាពអាចប្រព្រឹត្តិទៅបាន។ កម្មវិធីអប់រំពួកអ្នកទោសដែលមិនចេះអក្សរនិងពួកអ្នកទោសក្មេងៗត្រូវតែឲ្យមាន


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ដោយខានពុំបាន។ ក្រុមអភិបាលមន្ទីរត្រូវយកចិត្តទុកដាក់ឲ្យបានដិតដល់ចំពោះអ្នកទោសក្រុមនេះ ។

(២) ប្រសិនបើអាចអនុវត្តទៅបាន គួរយកកម្មវិធីអប់រំដែលគេប្រើនៅសាលារៀនធម្មតា ទៅបញ្ចូលក្នុងកម្មវិធី អប់រំនៅសាលាក្នុងមន្ទីរឃុំឃាំង ដើម្បីជួយសំរួលឲ្យពួកអ្នកទោស អស់ទាំងនេះ អាចបន្តការសិក្សាបានតទៅទៀតក្រោយពេល ចេញពីគុក។

៧៨. ដើម្បីថែរក្សាសុខភាពអ្នកទោសទាំងខាងផ្លូវកាយ និងផ្លូវចិត្ត នៅក្នុងមន្ទីរឃុំឃាំងត្រូវ រៀបចំឲ្យមានកម្មវិធីផ្នែក វប្បធម៌ ហើយនឹងពេលវេលាសំរាប់សំរាកកំសាន្ត។

## ការទាក់ទងក្នុងសង្គម និងការថែរក្សា ក្រោយពីចេញពីមន្ទីរឃុំឃាំង

៧៩. ត្រូវយកចិត្តទុកដាក់ជាពិសេសទៅលើវិន័យនៃការបង្កើនការទាក់ទង ឬការរក្សា ការទាក់ទងរវាងអ្នកទោស និង ក្រុមគ្រួសាររបស់គេ ដើម្បីជាប្រយោជន៍ដល់ពួកគេទាំងសង្ខាង។

៨០. ចាប់តាំងពីថ្ងៃដំបូងដែលអ្នកទោសចូលមកដល់គុក ត្រូវយកចិត្តទុកដាក់គិតគូរអំពី អនាគតរបស់គេ ក្រោយពី ពេលដែលគេបានចេញពីគុកទៅវិញ។ ត្រូវជួយណែនាំឲ្យអ្នកទោស ចេះរក្សាការទាក់ ទងជាមួយអ្នកក្រៅ ឬចេះរក្សាទំនាក់ទំនង ជាមួយអ្នកក្រៅ ឬទីភ្នាក់ងារផ្សេងៗ នៅក្រៅគុក ដែលជាកត្តាអាចជួយឲ្យរីកចំរើនក្នុងការកសាងខ្លួនគេ និងជាការបង្កើន ប្រយោជន៍ ដល់បងប្អូនគ្រួសារគេផង។

៨១. (១) កិច្ចឧបត្ថម្ភ ឬទីភ្នាក់ងាររបស់រដ្ឋាភិបាលឬរបស់ឯកជនទាំងឡាយណាដែល ចាំជួយ អ្នកទោសដែលរួចពីគុក ដើម្បីឲ្យរស់កើតនៅក្នុងសង្គមមនុស្ស ត្រូវគិតគូឲ្យដិតដល់ ទៅលើសេចក្តីត្រូវ ការសំខាន់ៗរបស់ពួកគេដូចជា ឯកសារឬសំបុត្រស្នាមសំគាល់ខ្លួន ផ្ទះសម្បែង សម្រាប់រស់នៅការងារ សំរាប់ធ្វើដើម្បីបានកម្រៃចិញ្ចឹមជីវិត សំលៀកបំពាក់គ្រប់គ្រាន់និងសមរម្យ ទៅតាមកាលៈទេសៈ និងធាតុអាកាស មធ្យោបាយគ្រប់គ្រាន់ដើម្បីធ្វើដំណើរទៅកាន់ទីដៅរបស់គេ និងថែរក្សាខ្លួនគេក្នុងរយៈ ពេលដំបង្អូរ ចាប់ពីថ្ងៃ ដែលគេចេញពីគុកភ្លាម។

(២) តំណាងទីភ្នាក់ងារនានាដែលអភិបាលមន្ទីរទទួលស្គាល់ ត្រូវមានលទ្ធភាព អាចចេញចូលមន្ទីរឃុំឃាំងបាន ដើម្បីជួបប្រាស្រ័យជាមួយពួកអ្នកទោសក្នុងការពិគ្រោះអំពី អនាគតរបស់ពួកគេ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(៣) ជាការកាន់តែប្រសើរ បើអាចធ្វើទៅបាន សកម្មភាពនានារបស់ទីភ្នាក់ងារផ្សេងៗគ្នាទាំងនេះ គួរធ្វើ តាមរយៈការិយាល័យកណ្តាលមួយជាមួយគ្នា ហើយគួរឲ្យមានការរួមសហប្រតិបត្តិការពីសំណាក់ទីភ្នាក់ងារផ្សេងៗ ដើម្បីឲ្យ ការខំប្រឹងប្រែងទាំងនេះ បានសំរេចជោគជ័យតាមគោលដៅ។

## ខ-អំពីអ្នកទោសឆ្កួតនិងអ្នកទោសដែលខូចខួរក្បាល

៨២. (១) បើពិនិត្យឃើញថាមានអ្នកទោសណាម្នាក់ឆ្កួតមិនត្រូវទុកឲ្យនៅក្នុងគុកជាមួយអ្នកទោសទៀតឡើយ ពោលគឺត្រូវយកទៅដាក់នៅមន្ទីរព្យាបាលជម្ងឺវិកលចរឹតភ្លាមមួយរំពេច។

(២) ពួកអ្នកទោសទាំងឡាយណាដែលមានជម្ងឺខួរក្បាល ឬមានខួរក្បាលមិនប្រក្រតីត្រូវដាក់អោយនៅក្រោម ការពិនិត្យ និងក្រោមការព្យាបាលរបស់គ្រូពេទ្យឯកទេសនៅមន្ទីរព្យាបាលរបស់គេ ដែលមានការគ្រប់គ្រងយ៉ាងពេញលេញពី ក្រសួងពេទ្យ។

(៣) ប្រសិនបើនៅក្នុងគុក ពួកអ្នកទោសប្រភេទនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់បុគ្គលិកពេទ្យ។

(៤) ទោះនៅមន្ទីរឃុំឃាំងធម្មតាក្តី ប្រសិនបើមានអ្នកទោសមានជម្ងឺខួរក្បាលមន្ទីរត្រូវតែផ្តល់កិច្ចព្យាបាល ផ្នែកជម្ងឺខួរក្បាលនេះអោយបានទាន់ពេលវេលា។

៨៣. ការដែលគួរឲ្យចង់បានគឺថា ប្រសិនបើឃើញថាមានការចាំបាច់គួរចាត់វិធានការដោយមានសម្រួលការជាមួយ ទីភ្នាក់ងារសមស្របឲ្យមានការតាមពិនិត្យព្យាបាលជាបន្តទៀតចំពោះអ្នកទោស (ដែលធ្លាប់មានជម្ងឺខួរក្បាល) ដែលបានចេញ ពីមន្ទីរឃុំឃាំង ហើយក្រោយពីបានព្យាបាលរួចហើយ ត្រូវឲ្យមានវិធីអប់រំណែនាំពួកទាំងនេះឲ្យចេះរស់នៅក្នុងសង្គមបានផង។

## គ-ជនដែលត្រូវគេចាប់ខ្លួន ឬរង់ចាំថ្ងៃកាត់ទោស

៨៤. (១) ជនដែលត្រូវគេចាប់ខ្លួនឬជាប់គុកដោយការចោទប្រកាន់ពីបទឧក្រិដ្ឋ ទោះនៅក្នុងមន្ទីរឃុំឃាំងនៃទីស្នាក់ការ នគរបាល ឬនៅក្នុងគុកក្តី ដែលចៅក្រមមិនទាន់កាត់សេចក្តីផ្តន្ទាទោសនៅឡើយនោះ ត្រូវចាត់ទុកថា “អ្នកជាប់ឃុំដែលមិនទាន់ កាត់ទោស” ដូចដែលមានចែងនៅបទបញ្ញាខាង ក្រោមនេះ ៖

(២) អ្នកទោសទាំងឡាយដែលចៅក្រមឬតុលាការពុំបានសំរេចថាមានទោសនៅឡើយត្រូវចាត់ទុកជាមនុស្ស គ្មានកំហុស ហើយត្រូវបានទទួលការថែទាំដូចមនុស្សធម្មតា ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(៣) ដោយពុំអោយមានទំនាស់ទៅនឹងបទបញ្ញាស្របច្បាប់ ដែលចែងអំពីកិច្ចការពារសេរីភាពរបស់មនុស្សម្នាក់ៗឬអំពីនីតិវិធីដែលត្រូវប្រតិបត្តិតាម ក្នុងករណីនៃពួកអ្នកជាប់ឃុំដែលមិនទាន់កាត់ទោស ពួកអ្នកជាប់ឃុំឃាំងទាំងនេះ មានសិទ្ធិទទួលកិច្ចការពារតាមរបៀបពិសេសមួយ ដែលមានរៀបរាប់ក្នុងបទបញ្ញាខាងក្រោមនេះ នៅក្នុងភាគនៃសេចក្តីតម្រូវ ដ៏សំខាន់របស់វា ។

៨៥. (១) អ្នកជាប់ឃុំឃាំងដែលគេមិនទាន់កាត់ទោស ត្រូវដាក់ឲ្យនៅដាច់ដោយឡែកអំពីអ្នកទោសដែលបានទទួល ការកាត់ទោស និងដាក់ទណ្ឌកម្មរួចហើយ ។

(២) អ្នកទោសក្មេងៗ ដែលពុំទាន់ទទួលការកាត់ទោស ត្រូវដាក់ឲ្យនៅដោយឡែកអំពីអ្នកទោសពេញវ័យ ហើយបើតាមគោលការណ៍ គួរដាក់ក្មេងៗ ទាំងនោះនៅក្នុងមន្ទីរដោយឡែក ។

៨៦. ត្រូវឲ្យអ្នកជាប់ឃុំឃាំងដែលមិនទាន់បានកាត់ទោស ដេកតែម្នាក់ឯងនៅក្នុងបន្ទប់ដោយឡែកពីគ្នា ដោយត្រូវ រៀបចំឲ្យមានធាតុអាកាសសមរម្យ ស្របទៅតាមទម្លាប់នៃតំបន់និមួយៗ របស់ អ្នកទោសម្នាក់ៗ។

៨៧. ចំពោះអ្នកទោសប្រភេទនេះ ប្រសិនបើគេចង់ ត្រូវអនុញ្ញាតិឲ្យគេទិញម្ហូបអាហារពីខាងក្រៅមកបរិភោគ ទោះ តាមរយៈក្រសួងរដ្ឋាភិបាល ឬតាមរយៈបងប្អូនគ្រួសារ ឬមិត្តភក្តិក្តី។ កាធ្វើបែបនេះ ត្រូវឲ្យស្របទៅតាមក្របខ័ណ្ឌនៃរបៀបរៀបរយរបស់មន្ទីរ។ ប៉ុន្តែបើគេមិនចង់ទិញម្ហូបពីក្រៅមក ទេអភិបាលមន្ទីរត្រូវទទួលបន្ទុកផ្តល់ម្ហូបអាហារដល់ពួកគេ។

៨៨. (១) ត្រូវអនុញ្ញាតិឲ្យពួកអ្នកទោសប្រភេទនេះប្រើសំលៀកបំពាក់របស់គេ ប្រសិនបើមានភាពស្អាតបាតត្រឹមត្រូវល្អ។

( ២) ប្រសិនបើគេត្រូវប្រើសំលៀកបំពាក់របស់មន្ទីរ សំលៀកបំពាក់ទាំងនេះមិនត្រូវឲ្យដូចគ្នាទៅនឹងខោអាវ របស់ពួកអ្នកទោសដែលតុលាការបានកាត់ទោសដាក់ទណ្ឌកម្មរួចហើយនោះទេ។

៨៩. ត្រូវអនុញ្ញាតិអោយអ្នកទោសប្រភេទនេះធ្វើការងារ ប៉ុន្តែមិនត្រូវតម្រូវបង្ខំគេឡើយ។ ប្រសិនបើគេចង់ធ្វើការ គេត្រូវបានទទួលប្រាក់កម្រៃ ឬប្រាក់ឈ្នួលពីការងារនេះ។


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៩០. អ្នកទោសប្រភេទនេះមានសិទ្ធិទិញ ឬអាចឲ្យបងប្អូនមិត្តភក្តិទិញឲ្យ នូវវត្ថុផ្សេងៗ ដូចជា សៀវភៅ កាសែត គ្រឿងប្រដាប់សរសេរ. ឲ្យតែស្របទៅនឹងផ្នែករបៀបរៀបរយរបស់មន្ទីរឃុំឃាំង។

៩១. ប្រសិនបើពិតជាឃើមែន ហើយបើគេមានប្រាក់គ្រប់គ្រាន់សំរាប់បង់ថ្លៃព្យាបាលអ្នកទោស ប្រភេទនេះមានសិទ្ធិជួលគ្រូពេទ្យឬពេទ្យធ្មេញពីខាងក្រៅឲ្យមកព្យាបាលរោគគេនៅក្នុងមន្ទីរឃុំឃាំងបាន។

៩២. ត្រូវអនុញ្ញាតិឲ្យអ្នកទោសប្រភេទនេះ ប្រាប់ជាដំណឹងដល់បងប្អូនគ្រួសារគេភ្លាម អំពីរឿងដែលគេត្រូវជាប់ឃុំ។ ត្រូវឲ្យពួកគេមានការទាក់ទងជាមួយគ្រួសារ ឬមិត្តភក្តិ និងអនុញ្ញាតិឲ្យពួកគេ ទាំងនេះចូលមកសួរសុខទុក្ខអ្នកទោសដែរ។ ប៉ុន្តែការទាក់ទងគ្នានេះត្រូវស្ថិតនៅក្នុងល័ក្ខខ័ណ្ឌនៃការ ត្រួតពិនិត្យណាដែលជាការចាំបាច់សំរាប់រក្សាយុត្តិធម៌ សន្តិសុខ និងរបៀបរៀបរយក្នុងមន្ទីរ។

៩៣. ត្រូវអនុញ្ញាតិឲ្យអ្នកទោសដែលមិនទាន់បានទទួលការកាត់ទោស រកជំនួយផ្នែកតុលាការ ដូចជាអ្នកច្បាប់ ឬស្មារតី ជាដើម ដើម្បីការពារខ្លួនគេ។ ហើយត្រូវអនុញ្ញាតិឲ្យទីប្រឹក្សាខាងច្បាប់ចូលជួប អ្នកទោសទាំងនេះ ក្នុងគោលដៅរៀបចំការការពារខ្លួនសំរាប់ថ្ងៃកាត់សេចក្តីនៅមុខតុលាការ។ ទីប្រឹក្សាខាងច្បាប់របស់អ្នកទោសម្នាក់ៗ អាចផ្តល់ឯកសារសំងាត់ផ្សេងៗឲ្យទោសអ្នកទោសដែលគេការពារ។ ឯការសម្ភាស (ឬការជួបគ្នា) រវាងទីប្រឹក្សាច្បាប់និងអ្នកទោស អាចប្រព្រឹត្តិទៅបាននៅក្នុងមន្ទីរឃុំឃាំងក្នុងស្ថានភាពដែលពួកតម្រួតប្រចាំមន្ទីរអាចមើលឃើញ តែមិនអាចស្តាប់ឮនូវការពិភាក្សានេះទេ។

## ឃ-អ្នកទោសបទរដ្ឋប្បវេណី
## (បទស៊ីវិល)

៩៤. នៅប្រទេសដែលមានច្បាប់ដាក់គុកព្រោះរឿងបំណុល ឬយកមនុស្សទៅដាក់គុកដោយបញ្ជាពីតុលាការស្តីអំពីរឿងរ៉ាវដែលពុំមែនជាបទឧក្រិដ្ឋ) (គឺបទរដ្ឋប្បវេណី ឬបទស៊ីវិល) មិនត្រូវដាក់កំរិត ឬល័ក្ខខ័ណ្ឌឲ្យតឹងតែងហួសហេតុពេកទេ។ គឺគ្រាន់តែឲ្យមានវិន័យសមរម្យសំរាប់ការរក្សាសន្តិសុខ និងរបៀបរៀបរយក្នុងមន្ទីរតែប៉ុណ្ណោះបានហើយ។ វិការគ្រប់គ្រងរក្សា ត្រូវ


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

*ឲ្យដូចគ្នានឹងពួកអ្នកទោស ដែលមិនទាន់ទទួលការកាត់ទោស។ ប៉ុន្តែក្នុងករណីខ្លះ អ្នកទោសក្នុងបទស៊ីវិលនេះ ត្រូវគេតម្រូវ អោយធ្វើការដែរ។*

## ខ-មនុស្សដែលគេចាប់ឃុំឃាំងដោយគ្មានកំហុស

*៩៥. ជនដែលត្រូវគេចាប់ឃុំឃាំងខ្លួនដោយគ្មានកំហុស (នឹងច្បាប់រដ្ឋ) ត្រូវតែបានការទទួលថែរក្សាការពា តាមលំនាំ នៃច្បាប់ ដែលបានចែងនៅក្នុងភាគទីមួយ (ទាំងមូល) និងនៅក្នុងភាគទីពីរ (ត្រង់ផ្នែក គ) រីច្បាប់ដែលចែងនៅក្នុងមាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ក៏យកមកអនុវត្តក្នុងករណីនេះបានដែរ។ ចំពោះច្បាប់ដែលចែងនៅក្នុង ភាគទី ២ (ត្រង់ផែក ក) ក៏អាចយកទៅប្រើបានដែរ ឲ្យតែមានផលប្រយោជន៍ដល់ពពួកជនជំពូកនេះ ។*

**បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងអ្នកទោស** *បានអនុម័តដោយសន្និបាតរបស់អង្គការសហប្រជាជាតិ លើកទីមួយស្តីពីការបង្ការបទឧក្រិដ្ឋនិងការប្រព្រឹត្តិលើអ្នកទោស ដែលបានប្រារព្ធនៅឯទី ក្រុងហ្សឺណែវ ក្នុងឆ្នាំ ១៩៥៥ ហើយនឹងបានយល់ព្រមដោយក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម តាមសេចក្តីសំរេចលេខ ៦៦៣* C (XXIV) *ចុះថ្ងៃ ទី ៣១ ខែ កក្កដា ១៩៥៧ និងសេចក្តីសម្រេចលេខ ២០៧៦* ( LXII) *ចុះថ្ងៃ ទី ១៣ ខែ ឧសភា ១៩៧៧ ។*
Adopted by the First United Nations Congress on the Prevention of Crime and the Treatment of Offenders, held at Geneva in 1955, and approved by the Economic and Social Council by its resolutions 663 C (XXIV) of 31 July 1957 and 2076 (LXII) of 13 May 1977.

*ប្រភព៖*

*បកប្រែ៖*

*វាយឡើងវិញ៖ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលសំរាប់រៀបចំកាត់សេចក្តីមេដឹកនាំខ្មែរក្រហម*


*រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល*